ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...................សហវ.......

# សេចក្តីព្រាងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១

❋❋❋✧❋❋❋

## ១. សេចក្តីផ្តើម

១. ឈរលើមូលដ្ឋានគ្រឹះដ៏រឹងមាំនៃកត្តាសុខសន្តិភាពពេញលេញ, បូរណភាពទឹកដី, សាមគ្គីភាពជាតិ និងស្ថិរភាពនយោបាយ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី**, ប្រទេសកម្ពុជាសម្រេចបាននូវការអភិវឌ្ឍកាន់តែជាទីមោទនៈលើគ្រប់វិស័យ ជាមួយនឹងការរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច-ហិរញ្ញវត្ថុប្រកបដោយភាពល្អប្រសើរ ក្នុងរយៈពេលជាងពីរទសវត្សរ៍ចុងក្រោយនេះ ។ ការសម្រេចបានកំណើនសេដ្ឋកិច្ចដ៏រឹងមាំ បានបន្តរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយអត្រានៃភាពក្រីក្រ និងវិសមភាពសង្គម, បង្កើតការងារ និងជំរុញការអភិវឌ្ឍវិស័យឯកជន ។ ជាការពិតណាស់, ការធានាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយបរិយាប័ន្នគឺជារបៀបវារៈចម្បងរបស់រាជរដ្ឋាភិបាលកម្ពុជា ។ ដើម្បីបន្តសម្រេចបាននូវគោលដៅកំណើននេះក្នុងរយៈពេលមធ្យម រាជរដ្ឋាភិបាលបាននិងកំពុងអនុវត្តនូវគោលនយោបាយអាទិភាពប្រកបដោយឆន្ទៈខ្ពស់ រួមមានជាអាទិ៍ "**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤**" និង "**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣**" ព្រមទាំងវិធានការកែទម្រង់មុតស្រួចជាកញ្ចប់នានាសំដៅចូលរួមចំណែកសម្រួលដល់បរិយាកាសធុរកិច្ច, លើកកម្ពស់ភាពប្រកួតប្រជែង និងបង្កើនល្បឿននៃការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច ។

២. ដោយឡែកសម្រាប់ឆ្នាំ ២០២០ សេដ្ឋកិច្ចកម្ពុជា បាននិងកំពុងទទួលរងនូវផលប៉ះទង្គិចធ្ងន់ធ្ងរបង្កឡើងដោយការរីករាលដាលនៃជំងឺកូវីដ-១៩ ហើយជាលទ្ធផល សេដ្ឋកិច្ចកម្ពុជានឹងមានកំណើនអវិជ្ជមានដែលពុំធ្លាប់មានក្នុងប្រវត្តិសាស្ត្រទំនើបរបស់ខ្លួន ។ ជាមួយគ្នានេះ ស្ថាប័នអន្តរជាតិធំៗបានធ្វើសេចក្តីសន្និដ្ឋានថា សេដ្ឋកិច្ចកម្ពុជាស្ថិតក្នុងចំណោមសេដ្ឋកិច្ច ដែលនឹងទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរពីជំងឺកូវីដ-១៩ ក្នុងតំបន់អាស៊ាន ។ កត្តាសត្យានុម័តមួយចំនួនដែលបង្ហាញថា ការខាតបង់នៃសេដ្ឋកិច្ចកម្ពុជាមានទំហំធំធេង រួមមាន÷ ១). ផលប៉ះពាល់ដែលកើតចេញពីវិបត្តិកូវីដ-១៩ នេះ មានវិសាលភាពជាសកល និងមានល្បឿនលឿនជាងការរំពឹងទុក, ២). វិស័យដែលអូសទាញកំណើនសេដ្ឋកិច្ចកម្ពុជាបាននិងកំពុងទទួលរងផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរ ខណៈចន្ទល់កំណើនថ្មីនៅមិនទាន់អាចមានលទ្ធភាពជំនួសបាននៅឡើយ, ៣). មុនទទួលរងនូវផលប៉ះពាល់ដោយផ្ទាល់ពីវិបត្តិនេះ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

សេដ្ឋកិច្ចកម្ពុជាបានចាប់ផ្ដើមជាមួយនឹងសញ្ញាថមថយរួចស្រេចទៅហើយ តាមរយៈការបាត់បង់ខ្លះៗនូវភាពប្រកួតប្រជែងដោយសារការព្យួរ EBA លើមុខទំនិញនាំចេញមួយចំនួន, ៤). លទ្ធភាព និងប្រសិទ្ធភាពនៃវិធានការគាំទ្រ ជាពិសេសផ្នែកហិរញ្ញវត្ថុរបស់កម្ពុជានៅមានកម្រិត, ៥). ជំហរអភិក្រម និងជម្រើសវិធានការរបស់កម្ពុជាផ្ទាល់ ត្រូវស្រប និងដើរទន្ទឹមនឹងប្រទេសជិតខាង និងតំបន់ ដែលនេះហាក់កំពុងដាក់កំហិតបន្ថែមលើកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា និង ៦). កម្ពុជាត្រូវត្រៀមសម្របខ្លួនជាមួយនឹងការប្រែប្រួលនៃនិន្នាការសកល ឬអាចជាប្រក្រតីកម្មថ្មី (new normal) ដែលនេះទាមទារនូវពេលវេលា និងការគិតគូរឱ្យបានគ្រប់ជ្រុងជ្រោយ ។

៣. ជាងនេះទៅទៀត ផលប៉ះទង្គិចនេះអាចនឹងមានទំហំ និងវិសាលភាពកាន់តែធំ ប្រសិនបើការរីក-រាលដាលនៃជំងឺកូវីដ-១៩ នៅអូសបន្លាយពេលកាន់តែយូរ ។ ជាក់ស្ដែង គិតត្រឹមជិតមួយឆមាសដើមឆ្នាំ ២០២០ នេះ, មូលដ្ឋានសេដ្ឋកិច្ចកម្ពុជាចាប់ផ្ដើមផ្ដល់នូវសញ្ញារង្គោះរង្គើជាបណ្ដើរៗ ជាពិសេសលើវិស័យទ្រទ្រង់កំណើន ។ ក្នុងន័យនេះ ផលប៉ះពាល់ធ្ងន់ធ្ងរអាចទៅហួសពីទិដ្ឋភាពសេដ្ឋកិច្ច ពោលគឺជ្រៀតចូលដល់ទិដ្ឋភាពសង្គម និងសន្តិសុខ តាមរយៈការកើនឡើងនៃអត្រាអត់ការងារធ្វើ, ការបាត់បង់ចំណូល, និងការធ្លាក់ចូលក្នុងភាពក្រីក្រធ្ងន់ធ្ងរ ដែលនេះនឹងនាំមកនូវបញ្ហាប្រឈមកាន់តែស្មុគស្មាញបន្ថែមទៀត ។ ជាការពិតណាស់ រាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងគិតគូរ និងដាក់ចេញនូវវិធានការទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព ដើម្បីកាត់បន្ថយទំហំនៃផលប៉ះពាល់ជាអតិបរមា ជាពិសេសការពារអាយុជីវិត និងរក្សាលំនឹងជីវភាពរស់នៅរបស់ប្រជាជន ។

៤. បើទោះមានសញ្ញានៃភាពវិជ្ជមានខ្លះៗពីការវិវត្តនៃវិបត្តិជំងឺកូវីដ-១៩ ក្នុងបណ្ដាប្រទេស និងតំបន់នានា, ការបិទបញ្ចប់នៃវិបត្តិនេះនៅតែជាមន្ទិលនៅឡើយ ។ ក្នុងន័យនេះ ឆ្នាំ ២០២១ ក៏ប្រហែលនៅតែជាឆ្នាំដ៏លំបាកមួយសម្រាប់សេដ្ឋកិច្ចកម្ពុជា ក្នុងការវិលប្រឡប់ទៅរកប្រក្រតីភាព ឬសក្ដានុពលដូចដើម ។ នេះមានន័យថា វិធានការគោលនយោបាយក្នុងឆ្នាំ ២០២១ នៅតែបន្តផ្ដោតលើការដោះស្រាយក្នុងបរិការណ៍នៃការរីករាលដាលជំងឺកូវីដ-១៩ ។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលកម្ពុជានឹងបន្តប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺនេះ និងគាំទ្រការស្ដារ និងជំរុញការងើបឡើងវិញនៃសង្គម-សេដ្ឋកិច្ចកម្ពុជា តាមរយៈការដាក់ចេញនូវវិធានការគោលនយោបាយមុតស្រួច និងអាទិភាព ជាមួយនឹងការគាំទ្រផ្នែកធនធានហិរញ្ញវត្ថុឱ្យចំគោលដៅ និងទាន់ពេលវេលា ព្រមទាំងការពង្រឹងសមត្ថភាពស្ថាប័ន ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពខ្ពស់ ។ ជំងឺកូវីដ-១៩ មិនត្រឹមតែបាននិងកំពុងធ្វើឱ្យបណ្ដាប្រទេសនានាលើសកលលោក ព្រមទាំងកម្ពុជាផងដែរ ទទួលរងនូវការខាតបង់ផល-ប្រយោជន៍សេដ្ឋកិច្ចច្រើនលើសលប់ តាមរយៈការថយចុះផលិតកម្ម, ការបាត់បង់ការងារ, ការធ្លាក់ចុះប្រាក់ចំណូល និងការថយចុះតម្រូវការប្រើប្រាស់ប៉ុណ្ណោះទេ ប៉ុន្តែនឹងធ្វើឱ្យនិន្នាការសកលមានការប្រែប្រួលជារចនាសម្ព័ន្ធ ដែលអាចនឹងឈានដល់ប្រក្រតីកម្មថ្មី ក្នុងនោះ រួមមាន÷

**១). ការប្រែប្រួលនិម្មាបនកម្មសេដ្ឋកិច្ចសកល** (global economic architecture)÷ ការថមថយវិហូរពាណិជ្ជកម្មសកល ទាំងទំនិញ និងសេវាកម្ម តាមរយៈការផ្លាស់ប្ដូរច្រវាក់ផលិតកម្មសកល, ការថមថយវិហូរមូលធនសកល ដោយសារការធ្លាក់ចុះនៃតម្រូវការវិនិយោគ និងការធ្លាក់ចុះវិហូរមនុស្ស (people

movement) បណ្តាលមកពីការភ័យខ្លាចក្នុងការធ្វើដំណើរ និងការដាក់ចេញនូវបទដ្ឋានសុវត្ថិភាពថ្មី សម្រាប់ការធ្វើដំណើរ និងទេសចរណ៍;

**២). ការធ្លាក់ចុះផលិតភាពសកល÷** ការថយចុះកម្រិតនវានុវត្តន៍ និងភាពច្នៃប្រឌិត បណ្តាលមកពីការផ្លាស់ប្តូរទម្រង់ការងារជាក្រុមទៅជាការធ្វើការងារជាលក្ខណៈបុគ្គល ស្របពេលបរិបទមិនប្រាកដប្រជានឹងបង្កការលំបាកក្នុងការព្យាករ និងរៀបចំផែនការឱ្យបានគ្រប់ជ្រុងជ្រោយ ។ បច្ចេកវិទ្យាថ្មី និងឌីជីថលដែលជាវិស័យគាំទ្រ អាចនឹងជួយប៉ះប៉ូវមួយផ្នែកដល់ការធ្លាក់ចុះនូវផលិតភាព ប៉ុន្តែមិនអាចជំនួសការធ្លាក់ចុះនូវផលិតកម្មក្នុងវិស័យផ្សេងៗទៀតបានឡើយ និង

**៣). ការកើនឡើងវិសមភាពសង្គម÷** ភាពក្រីក្រនឹងរីកធំដោយសារផលប៉ះទង្គិចមានសភាពធ្ងន់ធ្ងរ ទន្ទឹមនឹងវិធានការអន្តរាគមន៍របស់រាជរដ្ឋាភិបាលនៅមានកម្រិត ទាំងទំហំ និងប្រសិទ្ធភាព ។

និន្នាការទាំងអស់នេះ ទាមទារឱ្យរាជរដ្ឋាភិបាលត្រៀមខ្លួនជាស្រេច ក្នុងការដាក់ចេញនូវវិធានការដោះស្រាយជាកញ្ចប់ដោយធ្វើការថ្លឹងថ្លែងរវាងផលប្រយោជន៍សេដ្ឋកិច្ច, សុខភាពសាធារណៈ, សង្គម និងនយោបាយ ទាំងក្នុងរយៈពេលខ្លី និងមធ្យមខាងមុខ ។

៥. និន្នាការសកលបានបង្ហាញថា មានអភិក្រម ០២ ក្នុងការឆ្លើយតបនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងនោះគឺ÷

**អភិក្រមទី១÷** រង់ចាំរហូតដល់ការបញ្ចប់នៃវិបត្តិជំងឺកូវីដ-១៩ ទាំងស្រុង (បន្ទាប់ពីការរកឃើញនូវវ៉ាក់សាំង និងថ្នាំព្យាបាល) ដែលនេះនឹងធ្វើឱ្យមានបច្ច័យអវិជ្ជមានធ្ងន់ធ្ងរ ចំពោះសង្គម-សេដ្ឋកិច្ច និង

**អភិក្រមទី២÷** សម្របខ្លួនទៅនឹងជំងឺនេះ (រៀនរស់ជាមួយជំងឺនេះ) តាមរយៈការរៀបចំប្រព័ន្ធថ្នាក់ជាតិដោយផ្តោតសំខាន់លើតុល្យភាពរវាងការកាត់បន្ថយនៃការឆ្លងជាអតិបរមា និងសកម្មភាពសេដ្ឋកិច្ច ដើម្បីចាប់ផ្តើមដំណើរការ និងស្តារឡើងវិញនូវសកម្មភាពធុរកិច្ច និងពាណិជ្ជកម្ម ។

៦. ជម្រើសអភិក្រមណាមួយរបស់ប្រទេសក្នុងតំបន់ និងសកល នឹងមានឥទ្ធិពលដោយជៀសមិនរួចដល់ជំហរអភិក្រមរបស់កម្ពុជា និយាយជារួម និងនិយាយដោយឡែក លើការរៀបចំក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១ នេះ ។ ហេតុដូចនេះ សម្រាប់ជាការគិតគូរឱ្យកាន់តែគ្រប់ជ្រុងជ្រោយ រាជរដ្ឋាភិបាលនឹងកំណត់នូវជំហរអភិក្រមដែលមានលក្ខណៈប្រាកដនិយម និងស្របតាមនិន្នាការតំបន់ និងសកល ជាពិសេសអាចធានាបាន ទាំងលំនឹងសង្គម-សេដ្ឋកិច្ច និងសុវត្ថិភាពសុខភាពសាធារណៈ ដែលនឹងកំណត់ក្នុងក្របខ័ណ្ឌការស្តារឡើងវិញនៃសេដ្ឋកិច្ចក្រោយវិបត្តិជំងឺកូវីដ-១៩ ។

## ២. សមិទ្ធផលសេដ្ឋកិច្ចឆ្នាំ ២០១៩

៧. សេដ្ឋកិច្ចពិភពលោកមានកំណើនថមថយមកត្រឹម ២,៩% ក្នុងឆ្នាំ ២០១៩ ដែលបណ្តាលមកពីភាពតានតឹងនៃសង្គ្រាមពាណិជ្ជកម្មរវាងសហរដ្ឋអាមេរិក និងចិន, ភាពមិនប្រាកដប្រជានៃការចាកចេញរបស់រង់គ្លេសពីសហភាពអឺរ៉ុប, ការឡើងកំដៅនៃភូមិសាស្ត្រនយោបាយ ដែលបានដាក់សម្ពាធដល់ការវិនិយោគ និងទំនុកចិត្តរបស់អ្នកប្រើប្រាស់ ព្រមទាំងការបន្តនិន្នាការគោលនយោបាយគាំពារនិយម ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងឆ្នាំ ២០១៩, សេដ្ឋកិច្ចកម្ពុជាសម្រេចបានកំណើនខ្ពស់ក្នុងអត្រា ៧,១% ដែលទ្រទ្រង់ដោយការបន្តរីកចម្រើននៃវិស័យឧស្សាហកម្ម និងវិស័យសេវាកម្ម ខណៈវិស័យកសិកម្មមានកំណើនអវិជ្ជមាន ។ ការវាយតម្លៃជារួមបង្ហាញថា វិស័យឧស្សាហកម្មសម្រេចបានកំណើនក្នុងរង្វង់ ១១,៣% ដោយសារកំណើនខ្ពស់នៃអនុវិស័យសំណង់ និងអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ បើទោះបីជាអនុវិស័យកាត់ដេរមានកំណើនថមថយបន្តិច ។ ជាមួយគ្នានេះ, វិស័យសេវាកម្មត្រូវបានវាយតម្លៃថាសម្រេចបានកំណើន ៦,២% ដោយសារកំណើនយឺតនៃអនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន និងអនុវិស័យអចលនទ្រព្យ ខណៈដែលអនុវិស័យលក់ដុំ-រាយបន្តមានកំណើនល្អប្រសើរ ។ ចំណែកឯ វិស័យកសិកម្មត្រូវបានវាយតម្លៃថាមានកំណើនអវិជ្ជមាន ០,៥% ដោយសារកំណើនធ្លាក់ចុះនៃអនុវិស័យចិញ្ចឹមសត្វ និងនេសាទ ខណៈដែលអនុវិស័យដំណាំមានកំណើនទាប ។

៨. សម្រាប់ទិដ្ឋភាពហិរញ្ញវត្ថុសាធារណៈ, ក្នុងឆ្នាំ ២០១៩ រាជរដ្ឋាភិបាលបានអនុវត្តគោលនយោបាយពង្រឹងការគ្រប់គ្រងថវិកា (fiscal consolidation) ក្នុងគោលដៅបន្តពង្រឹងប្រសិទ្ធភាពចំណាយថវិការដ្ឋ តាមរយៈការវិភាជឱ្យកាន់តែចំគោលដៅ និងកាត់បន្ថយនូវចំណាយមិនចាំបាច់មួយចំនួន បន្ទាប់ពីអនុវត្តគោលនយោបាយវិត្ថារកម្មថវិកា (expansion fiscal policy) ក្នុងឆ្នាំ ២០១៨ ដែលបានជួយជំរុញកំណើនសេដ្ឋកិច្ចរហូតដល់ ៧,៥% ដែលជាកំណើនមួយខ្ពស់បំផុតក្នុងរយៈពេល ១០ ឆ្នាំ ចុងក្រោយនេះ ។ ក្នុងនោះ ការប្រមូលចំណូលក្នុងស្រុក សម្រេចបានកំណើនខ្ពស់ក្នុងអត្រា ២៦,២% សមមូលនឹង ២៥,២២% នៃ ផ.ស.ស ដែលជាលទ្ធផលល្អប្រសើរលើសការរំពឹងទុកនៃចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ ។ ជាមួយគ្នានេះ, ចំណាយថវិកាសរុបអនុវត្ត (បណ្តោះអាសន្ន)បានប្រមាណ ២៥,៧៥% នៃ ផ.ស.ស ស្មើនឹងកំណើន ១៦,៧% ដែលបានផ្តល់លទ្ធភាពដល់ការដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការ ព្រមទាំងកងកម្លាំងប្រដាប់អាវុធ និងពង្រីកការអនុវត្តគោល-នយោបាយគាំពារសង្គមផងដែរ ។ **ជារួម ឱនភាពថវិកាក្នុងឆ្នាំ ២០១៩ រក្សាបានក្នុងរង្វង់ ០,៥៣% នៃ ផ.ស.ស ។**

## ៣. ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

៩. មុនពេលមានវិបត្តិជំងឺកូវីដ-១៩ សេដ្ឋកិច្ចកម្ពុជាក្នុង ឆ្នាំ ២០២០ ត្រូវបានរំពឹងថាមានកំណើន ៦,៥% សម្រាប់ជាមូលដ្ឋានក្នុងការរៀបចំច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០ ។ ការព្យាករនេះ បានគិតគូររៀបចំក្នុងបរិបទដែលសេដ្ឋកិច្ចសកលមានកំណើនថមថយ និងការបន្តកើនឡើងនូវភាពមិនប្រាកដប្រជាខ្ពស់មកលើសេដ្ឋកិច្ចកម្ពុជា ជាពិសេសហានិភ័យនៃការដក EBA ខណៈដែលវិស័យទ្រទ្រង់កំណើនផ្សេងៗទៀតនៅ



4

បន្តកំណើនល្អប្រសើរធម្មតា ។ យ៉ាងណាមិញ ក្នុងបរិការណ៍បច្ចុប្បន្ន ស្ថាប័នអន្តរជាតិធំៗ បានព្យាករទម្លាក់កំណើនសេដ្ឋកិច្ចសកល និងកម្ពុជា ។

**១០.** ជាលទ្ធផល ក្នុងឆ្នាំ ២០២០ សេដ្ឋកិច្ចសកលត្រូវបានប៉ាន់ស្មានថានឹងមានកំណើនអវិជ្ជមាន ៣,០% ដោយសារផលប៉ះពាល់ដែលបណ្តាលមកពីការរីករាលដាលនៃជំងឺកូវីដ-១៩ ។ កំណើនអវិជ្ជមាននេះត្រូវបានឆ្លុះបញ្ចាំងតាមរយៈការធ្លាក់ចុះយ៉ាងគំហុកនៃសកម្មភាពផលិតកម្ម, ការវិនិយោគ, ការប្រើប្រាស់ និងការធ្វើដំណើរ ដោយសារវិធានការក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ របស់ប្រទេសនីមួយៗ ដូចជាការបិទទីក្រុង (lockdown) និងការដាក់កំហិតឱ្យនៅផ្ទះជាដើម ។ ក្នុងនោះ សេដ្ឋកិច្ចសហរដ្ឋអាមេរិក និងតំបន់ចាយប្រាក់អឺរ៉ូ ត្រូវបានវាយតម្លៃថានឹងទទួលរងផលប៉ះពាល់ខ្លាំង និងមានកំណើនអវិជ្ជមាន ៥,៩% និង ៧,៥% រៀងគ្នា ដោយសារការរីករាលដាលធ្ងន់ធ្ងរ និងនិន្នាការអូសបន្លាយនៃជំងឺកូវីដ-១៩ នៅក្នុងតំបន់ទាំងពីរនេះ ។ សេដ្ឋកិច្ចចិន ត្រូវបានប៉ាន់ស្មានថានឹងរក្សាបានកំណើនវិជ្ជមាន តែស្ថិតក្នុងកម្រិតទាប ក្នុងអត្រា ១,២% ដោយសារប្រសិទ្ធភាពនៃវិធានការទប់ស្កាត់ ដែលបានដាក់ចេញដោយរដ្ឋាភិបាលចិន ហើយសកម្មភាពសេដ្ឋកិច្ចចិនត្រូវបានរំពឹងថានឹងងើបឡើងវិញបន្តិចម្តងៗ ចាប់ពីត្រីមាសទី ២ ឆ្នាំ ២០២០ ។

**១១.** ដោយឡែកក្នុងឆ្នាំ ២០២១ សេដ្ឋកិច្ចសកលលោកត្រូវបានព្យាករថា នឹងងើបមកវិញក្នុងអត្រា ៥,៨% ក្រោមការរំពឹងទុកថាជំងឺនេះនឹងមានភាពធូរស្រាលជាបណ្តើរៗ ក្នុងឆមាសទី ២ ឆ្នាំ ២០២០ បូករួមនឹងលទ្ធផលទទួលបានពីគោលនយោបាយគាំទ្រសេដ្ឋកិច្ច ដែលបានដាក់ចេញដោយរដ្ឋាភិបាលក្នុងប្រទេសនីមួយៗ ដែលនឹងធ្វើឱ្យសកម្មភាពសេដ្ឋកិច្ចត្រឡប់មកសភាពធម្មតាវិញ ។ ទោះជាយ៉ាងនេះក្តី ការព្យាករនេះស្ថិតក្នុងភាពមិនប្រាកដប្រជាខ្ពស់ ដោយហេតុថានិន្នាការងើបឡើងវិញនេះអាស្រ័យលើរយៈពេលនៃការអូសបន្លាយ និងលទ្ធភាពនៃការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ ព្រមទាំងប្រសិទ្ធភាពនៃការឆ្លើយតបផ្នែកគោលនយោបាយរបស់រដ្ឋាភិបាលនៃប្រទេសនីមួយៗ ក្នុងការស្តារសេដ្ឋកិច្ចឡើងវិញ ។ ទន្ទឹមនេះ ការឡើងកម្តៅនៃភូមិសាស្ត្រនយោបាយរវាងសហរដ្ឋអាមេរិក និងចិន, បាតុកម្មនៅហុងកុងក្នុងពេលថ្មីៗនេះ និងបញ្ហាកោះតៃវ៉ាន់ ក៏ជាហានិភ័យចំពោះការងើបឡើងវិញនៃសេដ្ឋកិច្ចសកលលោកផងដែរ ។ ឈរលើហានិភ័យ និងភាពមិនប្រាកដប្រជាទាំងនេះ ស្ថាប័នអន្តរជាតិនានា នឹងធ្វើការព្យាករទម្លាក់កំណើនសេដ្ឋកិច្ចសកលជាថ្មីម្តងទៀតនាពេលឆាប់ៗខាងមុខនេះ ។

**១២.** ក្នុងឆ្នាំ ២០២០, *សេដ្ឋកិច្ចកម្ពុជាត្រូវបានប៉ាន់ស្មានថានឹងមានកំណើនអវិជ្ជមាន ១,៩% ដែលជាអត្រាមិនធ្លាប់មានកន្លងមក* ដោយសារការរីករាលដាលយ៉ាងលឿននៃជំងឺកូវីដ-១៩ ដែលបាននិងកំពុងធ្វើឱ្យតម្រូវការខាងក្រៅធ្លាក់ចុះយ៉ាងគំហុក និងរុញច្រានសេដ្ឋកិច្ចប្រទេសជាច្រើន ជាពិសេសបណ្តាប្រទេសដែលជាដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជាប្រឈមនឹងកំណើនអវិជ្ជមាន ។ ជាក់ស្តែង ជំងឺកូវីដ-១៩ បាននិងកំពុងបង្កឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយផ្ទាល់លើសេដ្ឋកិច្ចសហរដ្ឋអាមេរិក, សហភាពអឺរ៉ុប និងចិន តាមរយៈការធ្លាក់ចុះតម្រូវការ ទាំងទំនិញ និងសេវាកម្ម រួមទាំងការធ្វើដំណើរ និងការផ្អាក ឬការបង្អាក់ផលិតកម្ម ។ និន្នាការធ្លាក់ចុះនេះ នឹងធ្វើឱ្យវិស័យជំរុញកំណើនសំខាន់ៗរបស់កម្ពុជា ទទួលរងនូវផលប៉ះពាល់អវិជ្ជមាន ដូចជា÷ ១).

អនុវិស័យទេសចរណ៍ ដោយសារការដាក់កំហិតលើការធ្វើដំណើរ និងការភ័យខ្លាចនៃការឆ្លងជំងឺកូវីដ-១៩, ២). អនុវិស័យកាត់ដេរ ដោយសារការលុបចោលនូវការបញ្ជាទិញពីទីផ្សារអឺរ៉ុប និងសហរដ្ឋអាមេរិក ដែលកំពុងបង្ខំឱ្យរោងចក្រជាច្រើនព្យួរប្រតិបត្តិការ និងអាចឈានដល់ការបិទរោងចក្រ និង ៣). អនុវិស័យសំណង់ និងអចលនទ្រព្យ ដោយសារការធ្លាក់ចុះទំនុកចិត្តក្នុងការវិនិយោគ និងវំហូរទុនវិនិយោគ ព្រមទាំងការថមថយប្រាក់ចំណូលរបស់ប្រជាជន ។ យ៉ាងណាមិញ, ក្នុងឆ្នាំ ២០២១ សេដ្ឋកិច្ចកម្ពុជា ត្រូវបានរំពឹងថាអាចនឹងងើបឡើងវិញមកក្នុងអត្រាកំណើន ៣,៥% ដោយសារការរំពឹងទុកការងើបឡើងវិញយឺតនៃសកម្មភាពសេដ្ឋកិច្ច ជាពិសេសការកើនឡើងក្នុងកម្រិតទាបនៃតម្រូវការខាងក្រៅ និងទំនុកចិត្តទីផ្សារក្នុងស្រុក ។ ទន្ទឹមនេះ, គួរកត់សម្គាល់ផងដែរថា ការរំពឹងទុកនេះ គឺស្ថិតក្នុងភាពមិនប្រាកដប្រជាខ្ពស់ ដោយត្រូវពឹងផ្អែកលើកត្តាសត្យានុម័តមួយចំនួន ដូចជា ប្រសិទ្ធភាពនៃវិធានការគ្រប់គ្រងផលប៉ះពាល់ពីជំងឺកូវីដ-១៩ របស់កម្ពុជាផ្ទាល់, ក្នុងតំបន់ និងសកលលោក, លទ្ធភាពរកឃើញថ្នាំព្យាបាល ព្រមទាំងលទ្ធភាពផលិតនូវវ៉ាក់សាំងទ្រង់ទ្រាយធំ ក៏ដូចជាការអនុវត្តវិធានការដែលបានដាក់ចេញដើម្បីស្តារ និងស្រោចស្រង់សេដ្ឋកិច្ចក្រោយវិបត្តិកូវីដ-១៩ ប្រកបដោយប្រសិទ្ធភាព ។ ផ្អែកលើនិន្នាការខាងលើ, សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០២០ និង ២០២១ ត្រូវបានព្យាករដូចខាងក្រោម÷

**១៣.** *(១) វិស័យកសិកម្ម* ត្រូវបានព្យាករថានឹងមានកំណើនក្នុងរង្វង់អត្រា ០,៩% ក្នុងឆ្នាំ ២០២០ និងងើបឡើងវិញបន្តិចមកអត្រា ១,៦% ក្នុងឆ្នាំ ២០២១ ដោយសារការងើបឡើងវិញនៃអនុវិស័យចិញ្ចឹមសត្វ និងនេសាទ ។

**១៤.** អនុវិស័យដំណាំត្រូវបានព្យាករថានឹងសម្រេចបានកំណើន ០,៨% ក្នុងឆ្នាំ ២០២០ និង ១,៨% ក្នុងឆ្នាំ ២០២១ ដោយសារតែកំណើនល្អប្រសើរនៃផលិតកម្មកៅស៊ូ, ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម ខណៈដែលផលិតកម្មស្រូវបន្តកំណើនទាប បើទោះបីជាងើបឡើងវិញបន្តិចធៀបនឹងឆ្នាំ ២០១៩ ដែលបណ្តាលមកពីភាពមានកម្រិតនៃការពង្រីកផ្ទៃដីដាំដុះ, កំណើនផលិតភាពទាប និងឥទ្ធិពលអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ ។ ផលិតកម្មដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម ដូចជាដំឡូងមី, ស្វាយចន្ទី, ស្វាយ, ចេក, ពោត និងបន្លែ ជាដើម ត្រូវបានរំពឹងថានឹងបន្តកំណើនល្អ ដែលនឹងត្រូវបានជំរុញដោយការអនុវត្តវិធានការគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការជំរុញផលិតកម្មក្នុងស្រុក, ការកើនឡើងនៃការវិនិយោគក្នុងស្រុក និងបរទេសលើការកែច្នៃផលិតផលកសិកម្ម និងការរំពឹងទុកនូវការកើនឡើងនៃការនាំចេញផលិតផលកសិកម្មទៅកាន់ទីផ្សារចិន, ហុងកុង, កូរ៉េខាងត្បូង និងប្រទេសមួយចំនួនទៀតក្នុងតំបន់អាស៊ាន ។

**១៥.** អនុវិស័យនេសាទ ត្រូវបានព្យាករថានឹងងើបឡើងវិញបន្តិច ក្នុងអត្រា ១,៣% ក្នុងឆ្នាំ ២០២០ និង ១,៧% ក្នុងឆ្នាំ ២០២១ ដែលនឹងត្រូវបានជំរុញដោយកំណើននៃការវិនិយោគលើអនុវិស័យវារីវប្បកម្ម ដោយសារការអនុវត្តវិធានការរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ តាមរយៈការគាំទ្រផ្នែកហិរញ្ញប្បទានសម្បទាន, ការផ្សព្វផ្សាយបច្ចេកទេស និងការប្រើប្រាស់ពូជត្រីប្រកបដោយប្រសិទ្ធភាព និងគុណភាព ខណៈដែលផលចាប់ទឹក

សាបនៅបន្តកំណើនទាប ដោយសារការប្រែប្រួលអាកាសធាតុ ដែលធ្វើឱ្យទឹកទន្លេទាបមិនអំណោយផលដល់ការបង្កកំណើតរបស់ត្រី ។

**១៦.** អនុវិស័យចិញ្ចឹមសត្វ ត្រូវបានព្យាករថានឹងងើបឡើងវិញបន្តិចក្នុងរង្វង់អត្រា ១,១% ក្នុងឆ្នាំ ២០២០ និង ១,៦% ក្នុងឆ្នាំ ២០២១ ដោយសារការរំពឹងទុកនូវកំណើនការចិញ្ចឹមសត្វបែបពាណិជ្ជកម្មខ្នាតមធ្យម និងធំ ជាពិសេសការចិញ្ចឹមជ្រូក និងមាន់ ដែលជំរុញដោយភាពល្អប្រសើរនៃថ្លៃសត្វ ។ ជាមួយគ្នានេះដែរ, អនុវិស័យនេះក៏នឹងត្រូវជំរុញផងដែរ ដោយការងើបឡើងវិញនៃការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ ដោយសារអន្តរាគមន៍របស់រាជរដ្ឋាភិបាល និងការអនុវត្តគម្រោងរបស់ដៃគូអភិវឌ្ឍន៍នានា ដើម្បីជួយដល់ពលករចំណាកស្រុកដែលត្រឡប់ពីបរទេស និងកម្មករបាត់បង់ការងារក្នុងវិស័យកាត់ដេរ ក្នុងអំឡុងពេល និងក្រោយពេលជំងឺកូវីដ-១៩ ។

**១៧.** ទោះជាយ៉ាងនេះក្តី វិស័យកសិកម្មនៅជួបបញ្ហាប្រឈមជាលក្ខណៈរចនាសម្ព័ន្ធ ដូចជាកំណើនផលិតភាពទាប ទាំងផលិតភាពពលកម្ម និងផលិតភាពដី, ភាពនៅទន់ខ្សោយនៃការធ្វើពាណិជ្ជូបនីយកម្ម និងពិពិធកម្មកសិកម្ម, កង្វះការកែច្នៃផលិតផលកសិកម្មឱ្យអស់ពីសក្តានុពលដើម្បីបង្កើនតម្លៃបន្ថែមក្នុងសេដ្ឋកិច្ច, ភាពមានកម្រិតនៃការសម្របសម្រួលស្ថាប័ន និងការធ្វើសុខដុមនីយកម្មគម្រោងនានា ទាំងក្នុងកម្រិតនៃការធ្វើផែនការសកម្មភាព និងថវិកា និងកម្រិតនៃការអនុវត្ត ។ ក្នុងន័យនេះ ដើម្បីជំរុញវិស័យកសិកម្មឱ្យមានកំណើនខ្ពស់ឡើងវិញសំដៅគាំទ្រកំណើនសេដ្ឋកិច្ច, កាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់សន្តិសុខស្បៀង ក្នុងរយៈពេលមធ្យម និងវែង, រាជរដ្ឋាភិបាលនឹងបន្តផ្តោតអាទិភាពចម្បងលើការលើកកម្ពស់ផលិតភាព និងពិពិធកម្មកសិកម្ម ការជំរុញការកែច្នៃ និងការនាំចេញ ។ ដើម្បីសម្រេចគោលដៅនេះ រាជរដ្ឋាភិបាលនឹងបន្តអនុវត្តវិធានការគោលនយោបាយរួមមាន÷ ១). បង្កើនការវិនិយោគលើផលិតកម្មពូជសុទ្ធ ដែលមានគុណភាពល្អ, ២). ជំរុញការស្រាវជ្រាវ និងការអភិវឌ្ឍ, ៣). បង្កើនការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ដែលស្របនឹងតម្រូវការទីផ្សារ, ៤). ផ្តោតអាទិភាពលើការវិនិយោគលើប្រព័ន្ធស្រោចស្រពខ្នាតតូច និងមធ្យម ក្នុងតំបន់ដែលមានសក្តានុពលស្រូវក្រអូប និងដំណាំឧស្សាហកម្មផ្សេងទៀត, ៥). វិនិយោគហេដ្ឋារចនាសម្ព័ន្ធគាំទ្រផ្សេងទៀតដូចជាទីផ្សារបោះដុំកសិផល, មន្ទីរពិសោធន៍ និងឧបករណ៍ត្រួតពិនិត្យគុណភាព និងសុវត្ថិភាពផលិតផល, អនាម័យ និងភូតគាមអនាម័យ ដែលបម្រើដល់ការបង្កើនស្តង់ដារគុណភាពសម្រាប់បម្រើដល់ការនាំចេញ និង ៦). ធ្វើឱ្យប្រសើរឡើងនូវការសម្របសម្រួល និងសមត្ថភាពស្ថាប័នពាក់ព័ន្ធ ទាំងការធ្វើផែនការ និងការអនុវត្ត ប្រកបដោយប្រសិទ្ធភាព ។

**១៨.** ***(២) វិស័យឧស្សាហកម្ម*** ត្រូវបានប៉ាន់ស្មានថានឹងមានកំណើនអវិជ្ជមាន ២,២% ក្នុងឆ្នាំ ២០២០ ដោយសារការធ្លាក់ចុះគួរឱ្យកត់សម្គាល់នៃអនុវិស័យកាត់ដេរ និងសំណង់ ខណៈដែលអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរត្រូវបានរំពឹងថានឹងនៅបន្តកំណើនខ្ពស់ ។ ក្នុងឆ្នាំ ២០២១ វិស័យនេះត្រូវបានព្យាករថានឹងងើបឡើងក្នុងអត្រា ៤,១% ដោយសារការកើនឡើងវិញក្នុងកម្រិតទាបនៃអនុវិស័យកាត់ដេរ និងអនុវិស័យសំណង់ ខណៈដែលអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរនៅតែបន្តកំណើនល្អប្រសើរ ។

១៩. ក្នុងនោះ អនុវិស័យកាត់ដេរ ត្រូវបានប៉ាន់ស្មានថានឹងមានកំណើនអវិជ្ជមាន ៦,៧% ក្នុងឆ្នាំ ២០២០ ប៉ុន្តែត្រូវបានរំពឹងថាងើបឡើងមកវិញក្នុងអត្រាទាប ១,៦% ក្នុងឆ្នាំ ២០២១ ។ កំណើនអវិជ្ជមាននៃអនុវិស័យកាត់ដេរក្នុងឆ្នាំ ២០២០ នេះ ឆ្លុះបញ្ចាំងពីការធ្លាក់ចុះយ៉ាងគំហុកនៃតម្រូវការខាងក្រៅ ដោយសារផលប៉ះពាល់ធ្ងន់ធ្ងរនៃការរីករាលដាលជំងឺកូវីដ-១៩ ជាពិសេសលើប្រទេសដែលជាទីផ្សារនាំចេញសំខាន់ៗរបស់កម្ពុជាដូចជាសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប រហូតដល់បណ្តាលឱ្យមានការលុបចោលការបញ្ជាទិញចាប់ពីខែមេសា រហូតដល់ខែមិថុនា ឆ្នាំ ២០២០ ។ ក្នុងឆ្នាំ ២០២១, អនុវិស័យនេះត្រូវបានរំពឹងថានឹងកើនឡើងវិញក្នុងអត្រា ១,៦% ដោយសារការរំពឹងទុកការងើបឡើងយឺតនៃតម្រូវការខាងក្រៅ ។ ជាមួយគ្នានេះដែរ អនុវិស័យនេះក៏អាចប្រឈមនឹងការប្រកួតប្រជែងកាន់តែខ្លាំងពីការដណ្តើមយកទីផ្សារដែលទើបនឹងងើបឡើងមកវិញ បន្ទាប់ពីវិបត្តិនេះត្រូវបានគ្រប់គ្រង រួមទាំងផលប៉ះពាល់ដែលបណ្តាលមកពីការដកប្រព័ន្ធអនុគ្រោះពន្ធ EBA លើមុខទំនិញមួយចំនួន, ការចូលជាធរមាននៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងវៀតណាម និងសហភាពអឺរ៉ុប ព្រមជាមួយនឹងកំណើនទាបនៃផលិតភាពពលកម្ម ។ ជាការឆ្លើយតប, រាជរដ្ឋាភិបាលនឹងបន្តបង្កើនផលិតភាព, បញ្ចុះថ្លៃអគ្គិសនី, ដឹកជញ្ជូន និងឡូជីស្ទីក ព្រមទាំងលើកកម្ពស់កិច្ចសម្រួលពាណិជ្ជកម្មបន្ថែមទៀត ដើម្បីពង្រឹងភាពប្រកួតប្រជែងរបស់កម្ពុជាឱ្យកាន់តែប្រសើរឡើង ។

២០. អនុវិស័យសំណង់ ត្រូវបានប៉ាន់ស្មានថានឹងមានកំណើនអវិជ្ជមាន ៥,៣% ក្នុងឆ្នាំ ២០២០ និងរំពឹងថាងើបឡើងវិញជាមួយនឹងកំណើនទាបក្នុងអត្រា ៣,៣% ក្នុងឆ្នាំ ២០២១ ។ ក្នុងឆ្នាំ ២០២០ អនុវិស័យនេះមានការធ្លាក់ចុះយ៉ាងគំហុកមិនធ្លាប់មានចាប់តាំងពីវិបត្តិហិរញ្ញវត្ថុសកលអំឡុងឆ្នាំ ២០០៨-២០០៩ ដែលបណ្តាលមកពីការរំពឹងទុកនៃការធ្លាក់ចុះវិនិយោគពីបរទេស ជាពិសេសពីប្រទេសចិន និងតម្រូវការសាងសង់អគារបម្រើឱ្យវិស័យទេសចរណ៍ និងពាណិជ្ជកម្ម ព្រមទាំងការធ្លាក់ចុះទំនុកចិត្តវិនិយោគក្នុងស្រុកដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ ។ ក្នុងឆ្នាំ ២០២១ អនុវិស័យសំណង់ត្រូវបានរំពឹងថានឹងងើបឡើងវិញក្នុងអត្រាកំណើនទាប ដោយហេតុថាអនុវិស័យនេះត្រូវការពេលវេលា ដើម្បីស្តារទំនុកចិត្តសម្រាប់អ្នកវិនិយោគ ។ ជាមួយគ្នានេះដែរ, អនុវិស័យនេះពឹងផ្អែកខ្លាំងលើទុនវិនិយោគពីខាងក្រៅ ដូចនេះផលប៉ះពាល់អវិជ្ជមានពីវិបត្តិកូវីដ-១៩ និងបញ្ហាណាមួយដែលបង្អាក់ដល់កំណើនសេដ្ឋកិច្ចពិភពលោក នឹងបង្កជាហានិភ័យដល់អនុវិស័យសំណង់នៅកម្ពុជា ។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលនឹងបន្តឃ្លាំមើលដោយយកចិត្តទុកដាក់ និងធ្វើការសិក្សាឱ្យបានស៊ីជម្រៅ ពីការវិវត្តនៃអនុវិស័យសំណង់ និងអចលនទ្រព្យនៅកម្ពុជា ដើម្បីដាក់ចេញគោលនយោបាយអន្តរាគមន៍បានទាន់ពេលវេលាក្នុងការបញ្ចៀសហានិភ័យដែលអាចកើតឡើង ។

២១. អនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ ត្រូវបានព្យាករថានឹងបន្តកំណើនខ្ពស់ក្នុងរង្វង់ ១៣,១% ក្នុងឆ្នាំ ២០២០ និង ១០,១% ក្នុងឆ្នាំ ២០២១ ។ ក្នុងឆ្នាំ ២០២០ អនុវិស័យនេះត្រូវបានព្យាករថានឹងមានការកើនឡើង ដែលឆ្លុះបញ្ចាំងតាមរយៈកំណើនខ្ពស់នៃការនាំចេញផលិតផលមិនមែនកាត់ដេរ ដូចជា កង់, គ្រឿងបង្គុំអេឡិចត្រូនិក និងអង្ករ ព្រមទាំងការរំពឹងទុកការកើនឡើងផលិតកម្មក្នុងស្រុកសម្រាប់គាំទ្រដល់ការប្រើប្រាស់ក្នុងស្រុក ស្របពេលដែលការរីករាលដាលនៃជំងឺកូវីដ-១៩ ធ្វើឱ្យរាំងស្ទះដល់ការផ្គត់ផ្គង់ទំនិញនាំចូល ។ ក្នុងឆ្នាំ

២០២១ អនុវិស័យនេះត្រូវបានរំពឹងថានឹងបន្តកំណើនក្នុងអត្រា ១០,១% ដោយសារការពង្រីកមូលដ្ឋានផលិតកម្ម ផលិតផលមិនមែនកាត់ដេរនៃវិនិយោគដែលមានស្រាប់ ទាំងក្នុង និងក្រៅតំបន់សេដ្ឋកិច្ចពិសេស, ការរំពឹងទុក និន្នាការនៃការផ្លាស់ប្តូរទីតាំង (relocation) របស់រោងចក្រមួយចំនួនមកកម្ពុជា ដែលបណ្តាលមកពីឥទ្ធិពលនៃសង្គ្រាមពាណិជ្ជកម្ម និងការបង្វែរពីច្រវាក់ផលិតកម្មសកលមកជាច្រវាក់ផលិតកម្មតំបន់ក្នុងបរិការណ៍វិបត្តិកូវីដ-១៩ ។ ទន្ទឹមនេះ, ការដាក់ចេញជាបន្តបន្ទាប់នូវគោលនយោបាយគាំទ្រវិស័យឯកជន ជាពិសេសការអភិវឌ្ឍវិស័យសហគ្រាសធុនតូច និងមធ្យម និងការលើកកម្ពស់សហគ្រិនភាពដោយរាជរដ្ឋាភិបាល ត្រូវបានរំពឹងថានឹងជួយជំរុញដល់វិស័យនេះផងដែរ ។ ទោះជាយ៉ាងនេះក្តី, អនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ នៅតែមានការប្រឈមនឹងបញ្ហាជារចនាសម្ព័ន្ធមួយចំនួនដូចជា កង្វះវត្ថុធាតុដើមក្នុងស្រុក, ថ្លៃអគ្គិសនីខ្ពស់ និងកង្វះខាតប្រភេទអាជីវកម្មធុនកណ្តាល (missing middles) ដើម្បីផ្គត់ផ្គង់វត្ថុធាតុដើមដល់ឧស្សាហកម្មធំៗ ។ ដើម្បីឱ្យវិស័យនេះអាចរួមចំណែកឱ្យអស់សក្តានុពលនៅក្នុងសេដ្ឋកិច្ចជាតិ រាជរដ្ឋាភិបាលនឹងពន្លឿនការអនុវត្ត "**គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥**", ជំរុញយន្តការ "**គណៈកម្មាធិការសកម្មភាពគោលនយោបាយលើកស្ទួយសហគ្រាសធុនតូច និងមធ្យម**" ដើម្បីសម្របសម្រួល និងដោះស្រាយបញ្ហាជារចនាសម្ព័ន្ធ និងបញ្ហាផ្សេងៗ ដែលមានលក្ខណៈអន្តរស្ថាប័ន និងរៀបចំ "**ផែនការមេដើម្បីអភិវឌ្ឍខេត្តព្រះសីហនុ ទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង**" សំដៅផ្សារភ្ជាប់ខ្សែច្រវាក់តម្លៃតំបន់ និងសកល ក្នុងគោលដៅជំរុញពិពិធកម្មក្នុងវិស័យឧស្សាហកម្ម ។

**២២.** *(៣) វិស័យសេវាកម្ម* ត្រូវបានប៉ាន់ស្មានថានឹងធ្លាក់ចុះមកក្នុងអត្រាអវិជ្ជមាន ៣,0% ក្នុងឆ្នាំ ២០២០ ដោយសារការរំពឹងទុកនូវកំណើនអវិជ្ជមាននៃអនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន, អនុវិស័យលក់ដុំ-រាយ និងអនុវិស័យអចលនទ្រព្យ ។ វិស័យសេវាកម្មត្រូវបានព្យាករថានឹងកើនឡើងវិញមកក្នុងអត្រាកំណើនទាប ៣,៦% ក្នុងឆ្នាំ ២០២១ ដោយសារការរំពឹងទុកការងើបឡើងវិញក្នុងកម្រិតទាបនូវសកម្មភាពសេដ្ឋកិច្ច ជាពិសេសក្នុងវិស័យទេសចរណ៍ និងការប្រើប្រាស់ក្នុងស្រុក បន្ទាប់ពីវិបត្តិកូវីដ-១៩ ។

**២៣.** អនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន ត្រូវបានប៉ាន់ស្មានថានឹងមានកំណើនអវិជ្ជមាន ៩,៧% ក្នុងឆ្នាំ ២០២០ និងត្រូវបានព្យាករថាងើបឡើងវិញជាមួយនឹងអត្រា ៣,៨% ក្នុងឆ្នាំ ២០២១ ។ កំណើនអវិជ្ជមានក្នុងឆ្នាំ ២០២០ នេះ គឺដោយសារការរំពឹងទុកការធ្លាក់ចុះយ៉ាងគំហុកនៃចំនួនភ្ញៀវទេសចរជាតិ និងអន្តរជាតិ ដែលបណ្តាលមកពីការរីករាលដាលនៃជំងឺកូវីដ-១៩ ។ ក្នុងឆ្នាំ ២០២១, អនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន ត្រូវបានរំពឹងថានឹងមានកំណើនវិជ្ជមានឡើងវិញ ប៉ុន្តែស្ថិតក្នុងកម្រិតទាបនៅឡើយទាំងទំហំ និងអត្រាកំណើន ដោយសារការធ្លាក់ចុះលទ្ធភាពក្នុងការធ្វើដំណើរកំសាន្ត ហើយអនុវិស័យនេះអាចត្រូវការរយៈពេលពី ២ ទៅ ៣ ឆ្នាំ ដើម្បីអាចងើបទៅរកទំហំដែលធ្លាប់មានមុនពេលមានវិបត្តិ ។ ទន្ទឹមនេះ, វិស័យទេសចរណ៍នៅកម្ពុជានៅតែបន្តប្រឈមនឹងកង្វះខាតការធ្វើពិពិធកម្មគោលដៅ និងផលិតផលទេសចរណ៍, ភាពមានកម្រិតនៃសេវាទេសចរណ៍ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងស្ថាប័ន ព្រមទាំងការខាតបង់ចំណូល ដោយសារអវត្តមាននៃឧស្សាហកម្ម និងសេវាកម្មគាំទ្រ (backward linkages) ។ លើសពីនេះ, កម្ពុជានឹងប្រឈមនឹងការប្រកួតប្រជែងខ្ពស់ ដោយសារ

បណ្តាប្រទេសដែលជាគោលដៅទេសចរណ៍ដទៃទៀត សុទ្ធតែមានវិធានការរៀងៗខ្លួនក្នុងការស្រូបយកភ្ញៀវទេសចរបន្ទាប់ពីស្ថានភាពនៃវិបត្តិនេះបានធូរស្រាលេ ។ ក្នុងន័យនេះ, ដើម្បីបង្កើនទំនុកចិត្តភ្ញៀវទេសចរ, រាជរដ្ឋាភិបាលនឹងរៀបចំបទដ្ឋានសុវត្ថិភាពថ្មី និងវិធានការចាំបាច់ក្នុងអំឡុងពេល និងក្រោយបរិការណ៍ជំងឺកូវីដ-១៩ ។ អាជ្ញាធរពាក់ព័ន្ធ ក៏នឹងចាត់វិធានការក្នុងការរៀបចំឱ្យមានសណ្តាប់ធ្នាប់ និងរបៀបរៀបរយក្នុងតំបន់ទេសចរណ៍ ព្រមទាំងរៀបចំ និងដាក់ឱ្យអនុវត្តនូវផែនការរយៈពេលវែង ក្នុងការអភិវឌ្ឍវិស័យទេសចរណ៍នៅកម្ពុជា ដោយផ្តោតលើការកែលម្អការតភ្ជាប់ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការពង្រឹងសមត្ថភាពស្ថាប័ន, ការធ្វើពិពិធកម្មគោលដៅ និងផលិតផលទេសចរណ៍ឱ្យបានឆាប់រហ័ស និងការកែលម្អសេវាទេសចរណ៍ឱ្យមានគុណភាព ដើម្បីទាក់ទាញភ្ញៀវ-ទេសចរឱ្យធ្វើដំណើរកំសាន្តមកកម្ពុជាបន្ថែមទៀត ។

**២៤.** អនុវិស័យលក់ដុំ-រាយ ត្រូវបានព្យាករថានឹងមានកំណើនអវិជ្ជមាន ៤,០% ក្នុងឆ្នាំ ២០២០ និងរំពឹងថាងើបឡើងវិញមកក្នុងអត្រា ២,០% ក្នុងឆ្នាំ ២០២១ ។ កំណើនអវិជ្ជមានក្នុងឆ្នាំ ២០២០ ត្រូវបានឆ្លុះបញ្ចាំងតាមរយៈការធ្លាក់ចុះតម្រូវការប្រើប្រាស់ក្នុងស្រុក ដោយសារតែការធ្លាក់ចុះនៃអនុវិស័យសំខាន់ៗ ដែលជាប្រភពប្រាក់ចំណូលរបស់ប្រជាជន រួមមាន÷ វិស័យកាត់ដេរ, សំណង់, អចលនទ្រព្យ និងសណ្ឋាគារនិងភោជនីយដ្ឋានជាដើម ដែលបណ្តាលមកពីការរីករាលដាលនៃជំងឺកូវីដ-១៩ ។ យ៉ាងណាមិញ, ក្នុងឆ្នាំ ២០២១ កំណើននៃអនុវិស័យលក់ដុំ-រាយ ត្រូវបានព្យាករថានឹងងើបឡើងវិញ ប៉ុន្តែទាបជាងនិន្នាការធម្មតា ដោយសារឥទ្ធិពលនៃការថមថយចំណូលរបស់ប្រជាពលរដ្ឋក្នុងអំឡុងពេលមានវិបត្តិ ដែលនៅតែបន្តជះឥទ្ធិពលដល់តម្រូវការប្រើប្រាស់ ។ ការកើនឡើងនៃវិស័យលក់ដុំ-រាយ គឺពឹងផ្អែកទាំងស្រុងទៅលើលទ្ធភាពស្វែងរកចំណូលរបស់ប្រជាជន ដែលដើរស្របគ្នានឹងនិន្នាការរីកចម្រើននៃវិស័យផ្សេងៗក្នុងសេដ្ឋកិច្ចជាតិ ។ ដូច្នេះ រាជរដ្ឋាភិបាលនឹងបន្តដាក់ចេញនូវវិធានការ ដើម្បីរក្សាលំនឹងសេដ្ឋកិច្ច និងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ សំដៅធានានិរន្តរភាពការងារ និងចំណូល ។

**២៥.** អនុវិស័យអចលនទ្រព្យ ត្រូវបានព្យាករថានឹងមានកំណើនអវិជ្ជមាន ក្នុងអត្រា ៥,១% ក្នុងឆ្នាំ ២០២០ និងរំពឹងថានឹងងើបឡើងវិញជាមួយនឹងអត្រាកំណើនទាប ២,៦% ឆ្នាំ ២០២១ ។ ការធ្លាក់ចុះនេះ ឆ្លុះបញ្ចាំងតាមរយៈការរំពឹងទុកពីការធ្លាក់ចុះនៃលំហូរទុនវិនិយោគពីចិន និងទំនុកចិត្តវិនិយោគក្នុងស្រុក ដែលបណ្តាលមកពីការរីករាលដាលនៃជំងឺកូវីដ-១៩ ។ ដោយឡែក ក្នុងឆ្នាំ ២០២១ អនុវិស័យអចលនទ្រព្យត្រូវបានរំពឹងថានឹងងើបឡើងវិញក្នុងកម្រិតទាប ដោយសារតែការរំពឹងទុកនៃការកើនឡើងយឺតនៃលំហូរទុនវិនិយោគ និងសកម្មភាពសេដ្ឋកិច្ចទាំងក្នុង និងក្រៅប្រទេស ដែលជំរុញសកម្មភាពអចលនទ្រព្យ និងតម្រូវការក្នុងស្រុក ។ យ៉ាងណាមិញ, អនុវិស័យនេះ ក៏ប្រឈមនឹងហានិភ័យដូចគ្នាទៅនឹងអនុវិស័យសំណង់ ហើយទំនាក់ទំនងខ្ពស់រវាងអនុវិស័យនេះ និងវិស័យហិរញ្ញវត្ថុ ក៏បង្កជាក្តីបារម្ភចំពោះលទ្ធភាពនៃការកើតមានវិបត្តិហិរញ្ញវត្ថុ ស្របពេលដែលសកម្មភាពក្នុងអនុវិស័យនេះនឹងមានការធ្លាក់ចុះ ។ ដូច្នេះ ការបន្តតាមដានអនុវិស័យនេះប្រកបដោយការប្រុងប្រយ័ត្នខ្ពស់គឺជាការចាំបាច់ដើម្បីបញ្ចៀសនូវវិបត្តិដែលអាចកើតមានជាយថាហេតុ ។

២៦. អនុវិស័យដឹកជញ្ជូន និងគមនាគមន៍ ត្រូវបានព្យាករថាមានកំណើនថមថយគួរឱ្យកត់សម្គាល់មកក្នុងរង្វង់អត្រា ០,៤% ក្នុងឆ្នាំ ២០២០ និងងើបឡើងវិញក្នុងអត្រាកំណើន ៥,៩% ក្នុងឆ្នាំ ២០២១ ។ កំណើនទាបក្នុងឆ្នាំ ២០២០ នេះ ដោយសារការរំពឹងទុកនូវកំណើនអវិជ្ជមាននៃអនុវិស័យគាំទ្រដល់វិស័យដឹកជញ្ជូន រួមមានអនុវិស័យសំណង់, កាត់ដេរ និងសណ្ឋាគារ និងភោជនីយដ្ឋាន ជាដើម ។ ទោះជាយ៉ាងនេះក្តី, ការកើនឡើងខ្ពស់នៃការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ជាពិសេសក្នុងអំឡុងពេលការរីករាលដាលនៃជំងឺកូវីដ-១៩ នឹងជួយជំរុញដល់កំណើនក្នុងអនុវិស័យគមនាគមន៍ និងប៉ះប៉ូវដល់ការធ្លាក់ចុះនៃអនុវិស័យដឹកជញ្ជូន ។ ក្នុងឆ្នាំ ២០២១ អនុវិស័យនេះ ត្រូវបានរំពឹងថានឹងងើបឡើងវិញ បន្ទាប់ពីសកម្មភាពសេដ្ឋកិច្ចត្រឡប់រកភាពប្រក្រតី ហើយនិន្នាការកើនឡើងនៃការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត និងការវិនិយោគបន្ថែមលើហេដ្ឋារចនាសម្ព័ន្ធ នឹងបន្តជំរុញឱ្យអនុវិស័យគមនាគមន៍ កាន់តែរីកចម្រើនជាងមុនក្នុងរយៈពេលមធ្យម ។ អនុវិស័យដឹកជញ្ជូន និងគមនាគមន៍ ក៏ជួបប្រទះនឹងបញ្ហាប្រឈមមួយចំនួនផងដែរ រួមមាន ភាពទន់ខ្សោយនៃប្រព័ន្ធដឹកជញ្ជូន និងឡូជីស្ទីក ខណៈដែលការរៀបចំផែនការមេគ្រប់ជ្រុងជ្រោយនៃវិស័យនេះ មិនទាន់បានបញ្ចប់នៅឡើយ ។ ជាមួយគ្នានេះដែរ, ថ្លៃសេវាអ៊ីនធឺណិតនៅមានកម្រិតខ្ពស់ ប្រៀបធៀបនឹងប្រទេសក្នុងតំបន់ ។ រាជរដ្ឋាភិបាលត្រូវពន្លឿនការរៀបចំ និងដាក់ចេញនូវ **"ផែនការមេគ្រប់ជ្រុងជ្រោយ ស្តីពីប្រព័ន្ធដឹកជញ្ជូនពហុមធ្យោបាយ និងភស្តុភារកម្ម ២០២១-២០៣០"** និងវិធានការសម្រាប់អភិវឌ្ឍវិស័យដឹកជញ្ជូន និងគមនាគមន៍ ដើម្បីជំរុញដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលគាំទ្រដល់ការជំរុញកំណើនសេដ្ឋកិច្ចជាតិទាំងមូល ។

**តារាងទី១៖ កំណើនសេដ្ឋកិច្ចតាមវិស័យ**

| កំណើន (%) | ២០១៩ | ២០២០ប៉ាន់. | ២០២១ព្យា. |
|---|---|---|---|
| **កំណើន ផ.ស.ស** | **៧,១%** | **-១,៩%** | **៣,៥%** |
| **វិស័យកសិកម្ម** | -០,៥% | ០,៩% | **១,៦%** |
| ដំណាំ | ០,៦% | ០,៨% | ១,៨% |
| ការចិញ្ចឹមសត្វ | -២,៦% | ១,១% | ១,៦% |
| នេសាទ | -១,៦% | ១,៣% | ១,៧% |
| ព្រៃឈើ | -១,៨% | -១,៨% | -១,៨% |
| **វិស័យឧស្សាហកម្ម** | **១១,៣%** | **-២,២%** | **៤,១%** |
| កាត់ដេរ | ៦,៦% | -៦,៧% | ១,៦% |
| សំណង់ | ២០,៨% | -៥,៣% | ៣,៣% |
| កម្មន្តសាលមិនមែនកាត់ដេរ | ១០,៣% | ១៣,១% | ១០,១% |
| **វិស័យសេវាកម្ម** | **៦,២%** | **-៣,០%** | **៣,៦%** |
| សណ្ឋាគារ និងភោជនីយដ្ឋាន | ៣,១% | -៩,៧% | ៣,៨% |
| លក់ដុំ-រាយ | ៦,៥% | -៤,០% | ២,០% |
| ដឹកជញ្ជូន និងគមនាគមន៍ | ៨,៤% | ០,៤% | ៥,៩% |
| អចលនទ្រព្យ | ៧,០% | -៥,១% | ២,៦% |

ប្រភព: ការប៉ាន់ស្មាន និងការព្យាកររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ខែឧសភា ឆ្នាំ ២០២០

២៧. ជាមួយនឹងការងើបឡើងវិញនូវកំណើនសេដ្ឋកិច្ច, **អតិផរណា** ត្រូវបានព្យាករថានឹងស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបានក្នុងអត្រា ២,៨% ក្នុងឆ្នាំ ២០២០ ដោយសារការរំពឹងទុកការកើនឡើងនៃតម្រូវការ (demand shock) ម្ហូបអាហារ និងផលិតផលផ្សេងទៀតនៅលើទីផ្សារ ស្របពេលដែលការផ្គត់ផ្គង់ត្រូវបានរំពឹងថានឹងថមថយ ខណៈដែលថ្លៃដឹកជញ្ជូន ត្រូវបានប៉ាន់ស្មានថានឹងធ្លាក់ចុះ ទៅតាមនិន្នាការថ្លៃប្រេងលើទីផ្សារអន្តរជាតិ ។ ក្នុងឆ្នាំ ២០២១ អត្រានេះត្រូវបានព្យាករថានឹងស្ថិតក្នុងរង្វង់ ៣,១% ដោយសារការរំពឹងទុកការកើនឡើងបន្តិចមកវិញនូវថ្លៃប្រេងអន្តរជាតិ ។

២៨. ស្របជាមួយគ្នានេះដែរ **អត្រាប្តូរប្រាក់** រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកត្រូវបានរំពឹងថានឹងស្ថិតក្នុងរង្វង់ ៤ ១០០ រៀលក្នុងមួយដុល្លារអាមេរិក ក្នុងឆ្នាំ ២០២០ និង ២០២១ ។ ដើម្បីបន្តរក្សាជំនឿទុកចិត្តពីសំណាក់សាធារណជនលើការប្រើប្រាស់ប្រាក់រៀល និងស្ថិរភាពអត្រាប្តូរប្រាក់, ធនាគារជាតិនៃកម្ពុជានឹងបន្តអនុវត្តវិធានការលើកកម្ពស់ប្រាក់រៀល និងពង្រឹងគោលនយោបាយគ្រប់គ្រងសាច់ប្រាក់ ។

២៩. **ឱនភាពគណនីចរន្ត** (រួមបញ្ចូលបង្វែរ) ត្រូវបានប៉ាន់ស្មានថានឹងកើនឡើងដល់ទំហំ ១៧,៦% នៃ ផ.ស.ស ក្នុងឆ្នាំ ២០២០ ដោយសារការរំពឹងទុកការធ្លាក់ចុះនៃការនាំចេញ និងចំណូលជារូបិយប័ណ្ណដែលបានមកពីទេសចរអន្តរជាតិ ។ យ៉ាងណាមិញ, ទំហំនេះត្រូវបានព្យាករថានឹងរួមតូចបន្តិចមកត្រឹម ១៧,៣% នៃ ផ.ស.ស ក្នុងឆ្នាំ ២០២១ ដោយសារការរំពឹងទុកនៃការងើបឡើងវិញបន្តិចនូវការនាំចេញ និងវិស័យទេសចរណ៍ ។ ជាលទ្ធផល **ទុនបម្រុងអន្តរជាតិសរុប** ត្រូវបានរំពឹងថានឹងថយចុះក្នុងឆ្នាំ ២០២០ មកត្រឹម ១៦ ៩៣៧ លានដុល្លារអាមេរិក ដោយសារការរីកធំនៃឱនភាពគណនីចរន្ត រួមផ្សំនឹងការរំពឹងទុកការធ្លាក់ចុះរំហូរទុនវិនិយោគពីបរទេស ដែលទំហំនេះនៅតែអាចធានាការនាំចូលបាន ៨,៥ ខែ ។ ដោយឡែក ក្នុងឆ្នាំ ២០២១ ទុនបម្រុងអន្តរជាតិសរុប ត្រូវបានព្យាករថានឹងកើនឡើងដល់ ១៦ ៩៨១ លានដុល្លារអាមេរិក និងធានាការនាំចូលបាន ៨,០ ខែ ដោយហេតុថាការនាំចូលរបស់កម្ពុជាក៏នឹងងើបឡើងបន្តិចមកវិញ ។

**តារាងទី២÷ តារាងប៉ាន់ស្មានទំហំពាណិជ្ជកម្ម និងវិនិយោគផ្ទាល់ពីបរទេស**

| សូចនាករ | ២០១៩ | ២០២០ ប៉ាន់. | ២០២១ ព្យា. |
|---|---|---|---|
| ការនាំចេញ (លានដុល្លាររអាមេរិក) | ១៤ ៩៨៧ | ១៣ ៥៨៣ | ១៤ ៣៣៣ |
| ការនាំចូល (លានដុល្លារអាមេរិក) | ២២ ២៤២ | ២១ ៣១៤ | ២២ ៦០១ |
| ឱនភាពគណនីចរន្ត (លានដុល្លារអាមេរិក) | ៤ ២០៧ | ៤ ៧៩១ | ៥ ០១៩ |
| ការនាំចេញ (ភាគរយនៃ ផ.ស.ស) | ៥៥,២% | ៤៩,៩% | ៤៩,៤% |
| ការនាំចូល (ភាគរយនៃ ផ.ស.ស) | ៨២,០% | ៧៨,៣% | ៧៧,៩% |
| ឱនភាពសមតុល្យពាណិជ្ជកម្ម (ភាគរយនៃ ផ.ស.ស) | ២៦,៧% | ២៨,៤% | ២៨,៥% |
| ឱនភាពគណនីចរន្ត (ភាគរយនៃ ផ.ស.ស) | ១៥,៥% | ១៧,៦% | ១៧,៣% |

ប្រភព÷ ធនាគារជាតិនៃកម្ពុជា និងការព្យាកររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ខែឧសភា ឆ្នាំ ២០២០

៣០. បើទោះបីជាសេដ្ឋកិច្ចកម្ពុជា ក្នុងឆ្នាំ ២០២១ ត្រូវបានរំពឹងថានឹងងើបឡើងវិញក្នុងអត្រាដូចខាងលើក៏ដោយ, កម្ពុជាក៏ប្រឈមនឹងការកើនឡើងនៃហានិភ័យ ដោយសារភាពមិនប្រាកដប្រជា និងការប្រែប្រួលបរិបទសេដ្ឋកិច្ចសកល ។ ហានិភ័យទាំងនោះរួមមាន÷

(១). ផលប៉ះពាល់អវិជ្ជមានកាន់តែធ្ងន់ធ្ងរដោយសារការអូសបន្លាយ និងលទ្ធភាពនៃការកើតឡើងរលកទី ២ នៃជំងឺកូវីដ-១៩

(២). ការបន្តធ្លាក់ចុះសេដ្ឋកិច្ចពិភពលោក ដែលអាចឈានទៅដល់វិបត្តិសកលធ្ងន់ធ្ងរ (global depression)

(៣). ភាពតានតឹងនៃភូមិសាស្ត្រនយោបាយ និងសន្តិសុខសកលដែលអាចឈានទៅដល់សង្គ្រាមត្រជាក់ (cold war)

(៤). ភាពមិនប្រាកដប្រជានៃប្រព័ន្ធអនុគ្រោះពន្ធ និង

(៥). ការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ ។

៣១. ទន្ទឹមនឹងការកើនឡើងនៃហានិភ័យខាងក្រៅ, កម្ពុជានៅតែបន្តប្រឈមនឹងបញ្ហាក្នុងស្រុក បើទោះបីជារាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការគោលនយោបាយ ដើម្បីលើកកម្ពស់ភាពប្រកួតប្រជែង, ជំរុញពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពស្ថាប័នក្តី ។ បញ្ហាប្រឈមទាំងនោះរួមមាន÷

(១). ថ្លៃអគ្គិសនីនៅមានកម្រិតខ្ពស់ ដែលមិនទាន់មានភាពប្រកួតប្រជែង និងការផ្គត់ផ្គង់មិនទាន់មានស្ថិរភាព;

(២). ប្រព័ន្ធដឹកជញ្ជូន និងឡូជីស្ទីកដែលនៅមិនទាន់អាចប្រកួតប្រជែងបានជាមួយប្រទេសជិតខាង;

(៣). កិច្ចសម្រួលពាណិជ្ជកម្មដែលនៅបន្តជាបញ្ហាប្រឈមសម្រាប់ធុរជន;

(៤). សម្ពាធពីការកើនឡើងនៃប្រាក់ឈ្នួលអប្បបរមា ជាពិសេសសម្រាប់វិស័យឧស្សាហកម្ម ខណៈដែលកំណើនផលិតភាពពលកម្មនៅមានកម្រិតទាប;

(៥). ល្បឿនយឺតនៃការធ្វើពិពិធកម្មសេដ្ឋកិច្ច បើទោះបីជា "គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥" ត្រូវបានដាក់ចេញ ប៉ុន្តែប្រសិទ្ធភាពនៃការអនុវត្តនៅមានកម្រិត និង

(៦). បរិមាណ និងគុណភាពនៃកម្លាំងពលកម្មជំនាញ ដែលមិនទាន់អាចឆ្លើយតបនឹងតម្រូវការទីផ្សារ ។

៣២. *ដើម្បីឆ្លើយតបនឹងនិន្នាការខាងលើ ក៏ដូចជាគ្រប់គ្រងហានិភ័យ ដែលអាចកើតមាន រាជរដ្ឋាភិបាលនឹងដាក់ឱ្យអនុវត្តនូវវិធានការអន្តរាគមន៍សមស្រប និងទាន់ពេលវេលា តាមរយៈការដាក់ចេញដោយប្រទាក់ក្រឡានូវគោលនយោបាយហិរញ្ញវត្ថុសាធារណៈ, គោលនយោបាយរូបិយវត្ថុ និងគោលនយោបាយរចនាសម្ព័ន្ធ (structural policy) ដើម្បីសម្រេចឱ្យបានគោលបំណងរក្សាលំនឹងសេដ្ឋកិច្ច និងជំរុញកំណើនសេដ្ឋកិច្ច ។*

៣៣. (១) ***រក្សាលំនឹងសេដ្ឋកិច្ច៖*** តាមរយៈការបន្តការពារ និងប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩, ការបន្តរក្សាលំនឹងសកម្មភាពអាជីវកម្ម និងការបន្តរក្សាលំនឹងជីវភាពប្រជាជន ។

- *ការបន្តប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩៖* ការបង្កើនចំណាយលើវិស័យសុខាភិបាល និងកម្មវិធីលើកកម្ពស់សុខភាពសាធារណៈ ដែលផ្ដោតទាំងវិធានការការពារ (ការអប់រំ, ការបង្ការ និងការទប់ស្កាត់) និងវិធានការព្យាបាល ។
- *ការបន្តរក្សាលំនឹងសកម្មភាពអាជីវកម្ម៖* ការលើកទឹកចិត្ត និងអនុគ្រោះផ្នែកសារពើពន្ធ (tax relief), ការលើកលែង និងអនុគ្រោះឥណទាន (credit relief) និងការបង្កើនសន្ទនីយភាព (liquidity) ទៅក្នុងទីផ្សារ ជាពិសេសធ្វើយ៉ាងណាឱ្យអាជីវកម្មទាំងនោះអាចបន្តដំណើរការបាន ក្នុងដំណាក់កាលលំបាកនេះ ។
- *ការបន្តរក្សាលំនឹងជីវភាពប្រជាជន៖* ការអនុវត្តកម្មវិធីផ្ទេរសាច់ប្រាក់, កម្មវិធីសាច់ប្រាក់ពលកម្ម, កម្មវិធីបណ្ដុះបណ្ដាលជំនាញរយៈពេលខ្លី ដើម្បីបង្កើនលទ្ធភាពបង្កើតអាជីវកម្មផ្ទាល់ខ្លួន និងឈានទៅចាប់យកការងារក្នុងវិស័យថ្មី ឬវិស័យដែលប្រើបច្ចេកទេសខ្ពស់ជាងមុន, ការបង្កើតការងារថ្មីដើម្បីប៉ះប៉ូវការងារដែលបាត់បង់ ដោយបង្កើតវិនិយោគថ្មីៗក្នុងស្រុក និងទាក់ទាញវិនិយោគផ្ទាល់ពីបរទេស, ការជំរុញសកម្មភាពអាជីវកម្មរបស់សហគ្រាសធុនតូច និងមធ្យម និងការជួយសម្រួលការផ្លាស់ប្ដូរការងារពីវិស័យដែលទទួលរងផលប៉ះពាល់ពីជំងឺកូវីដ-១៩ ទៅវិស័យសក្ដានុពលផ្សេងទៀត ។

៣៤. (២) ***ជំរុញកំណើនសេដ្ឋកិច្ច៖*** តាមរយៈការបន្តបង្កើនភាពប្រកួតប្រជែង, ការបន្តជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបន្តកែទម្រង់រចនាសម្ព័ន្ធ ។

- *ការបន្តបង្កើនភាពប្រកួតប្រជែង៖* ការជួយសម្រួលក្នុងការកាត់បន្ថយថ្លៃដើម, ពេលវេលា និងបង្កើនភាពងាយស្រួលដល់ការធ្វើអាជីវកម្ម ដោយបន្តពង្រឹងកិច្ចសម្រួលពាណិជ្ជកម្ម; ការកាត់បន្ថយថ្លៃ និងធានាស្ថិរភាពនៃការផ្គត់ផ្គង់អគ្គិសនី; ការកាត់បន្ថយថ្លៃដឹកជញ្ជូន និងឡូជីស្ទីក; ការបង្កើនការតភ្ជាប់ឌីជីថល និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត; ការបង្កើនការបណ្ដុះបណ្ដាលជំនាញ; ការកាត់បន្ថយកម្រៃក្រៅផ្លូវការ; ការលើកកម្ពស់សេវាបង់ពន្ធ; ការកាត់បន្ថយការធ្វើសវនកម្មពន្ធដារត្រួតគ្នា និងការជំរុញការប្រកួតប្រជែងដោយស្មើភាព ។
- *ការបន្តជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច៖* ការជំរុញការធ្វើពិពិធកម្មផលិតកម្ម, សេវាកម្ម និងទីផ្សារ ។
    - **ការជំរុញការធ្វើពិពិធកម្មផលិតកម្ម និងសេវាកម្ម៖** ការអនុម័តច្បាប់វិនិយោគថ្មី, ច្បាប់ស្ដីពីការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស និងច្បាប់ស្ដីពីការប្រកួតប្រជែង; ការរៀបចំផែនការមេដើម្បីអភិវឌ្ឍខេត្តព្រះសីហនុ ឱ្យទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង; ការបន្តលើកទឹកចិត្តផ្នែកសារពើពន្ធ ដើម្បីលើកកម្ពស់សហគ្រាសធុនតូច និងមធ្យម និងសហគ្រិនភាព និងការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល ។
    - **ការជំរុញការធ្វើពិពិធកម្មទីផ្សារ៖** ការស្វែងរកទីផ្សារក្រៅស្រុកបន្ថែម ទាំងទ្វេភាគី និងពហុភាគី

តាមរយៈការពង្រីកទីផ្សារក្រៅប្រទេសទៅក្នុងប្លុកពាណិជ្ជកម្មថ្មីៗទាំង Cambodia-Eurasian Economic Union Free Trade Agreement, ASEAN-European Union Free Trade Agreement, Comprehensive and Progressive Agreement for Trans-Pacific Partnership និងពង្រឹងភាពជាដៃគូវិនិយោគ និងពាណិជ្ជកម្មទ្វេភាគី (ចិន+១, ជប៉ុន+១, ថៃ+១ និងវៀតណាម+១) ជាដើម ។

- *ការបន្តកែទម្រង់ជារបទាសម្ព័ន្ធ÷* ការពង្រឹងសមត្ថភាពស្ថាប័ន ក្នុងការដឹកនាំ និងការអនុវត្តគោល-នយោបាយ និងវិធានការនានា; ការបង្កើនប្រសិទ្ធភាពនៃការសម្របសម្រួលស្ថាប័ន ឬមុខងារ តាមរយៈការធ្វើវិចារណកម្មមុខងារ និងភារកិច្ច ព្រមទាំងការលើកកម្ពស់ភាពម្ចាស់ការ និងការទទួលខុសត្រូវខ្ពស់របស់ក្រសួង-ស្ថាប័ន; ការបង្កើនការអភិវឌ្ឍធនធានមនុស្ស ដោយផ្តោតសំខាន់ទាំងបរិមាណ និងគុណភាព ។

**៣៥.** ជារួម, ការសម្រេចបាននូវកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងរង្វង់ ៣,៥% អាស្រ័យលើលទ្ធផលនៃការអនុវត្តវិធានការអន្តរាគមន៍ ដែលមានលក្ខណៈប្រទាក់ក្រឡាប្រកបដោយប្រសិទ្ធភាព ដែលទាមទារនូវឆន្ទៈនយោបាយ និងសមត្ថភាពស្ថាប័នប្រកបដោយការទទួលខុសត្រូវខ្ពស់ ។

## ៤. ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

**៣៦.** ក្នុងបរិការណ៍នៃការរីករាលដាលយ៉ាងធ្ងន់ធ្ងរនៃជំងឺកូវីដ-១៩ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០ ត្រូវបានធ្វើវិចារណកម្ម ដើម្បីបង្វែរថវិកាឆ្ពោះទៅដោះស្រាយការងារអាទិភាពចំពោះមុខចំនួន ០៤ រួមមាន÷ ១). ប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩, ២). រក្សាលំនឹងជីវភាពប្រជាជនក្នុងកម្រិតអប្បបរមាមួយ (មិនឱ្យអត់បាយ) ជាពិសេសសម្រាប់ប្រជាជនក្រីក្រ និងអ្នកបាត់បង់ការងារ, ៣). ខិតខំជួយឱ្យអស់លទ្ធភាពដើម្បីឱ្យធុរកិច្ច និងអាជីវកម្មអាចរស់បាន និង ៤). រក្សាឱ្យបាននូវសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងស្ថិរភាពសង្គម ។

**៣៧.** ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២១ ដែលត្រូវបានរៀបចំដោយឈរលើមូលដ្ឋាននៃក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដូចបានគូសបញ្ជាក់ខាងលើ និង "**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤**" មានគោលបំណងដូចតទៅ÷

- បន្តពង្រឹងសន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ;
- បន្តរក្សាលំនឹង និងជំរុញកំណើនសេដ្ឋកិច្ច ក្នុងបរិការណ៍នៃជំងឺកូវីដ-១៩ តាមរយៈការជំរុញការនាំចេញឱ្យអស់ពីសក្តានុពល និងងាកពីការពឹងផ្អែកទាំងស្រុងលើតម្រូវការខាងក្រៅ មកពឹងផ្អែកមួយចំនួនលើតម្រូវការក្នុងស្រុក;
- បន្តធានានូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចក្នុងរយៈពេលមធ្យម ប្រកបដោយបរិយាបន្ន;

- បន្តអនុវត្តក្របខ័ណ្ឌចំណាយអន្តរាគមន៍ ដើម្បីដោះស្រាយបញ្ហាប្រឈមនានាចំពោះមុខ និងហានិភ័យនានា ប្រកបដោយប្រសិទ្ធភាពទាំងក្នុងកម្រិតវិភាជន៍ និងប្រតិបត្តិការ;
- ជំរុញការអនុវត្ត "**ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥**";
- គាំទ្រការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, កម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌; ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ;
- បង្កើនប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ឆ្នាំ ២០១៨-២០២៥;
- បន្តអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩-២០២៣ ប្រកបដោយប្រសិទ្ធភាពខ្ពស់សំដៅធានាបាននូវចីរភាពបំណុល;
- ពន្លឿនការអនុវត្តឱ្យបានខ្លាំងក្លានូវវិធានការនៃ "**គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ ២០១៥-២០២៥**" តាមរយៈការបន្តគាំទ្រការអភិវឌ្ឍវិស័យឯកជន និងសហគ្រាសធុនតូច និងមធ្យមជាមួយនឹងវិធានការជាក់លាក់ និងការបន្តវិនិយោគសាធារណៈលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តលើការតភ្ជាប់ក្នុងវិស័យដឹកជញ្ជូន, ថាមពល និងឌីជីថល;
- បន្តជំរុញការអភិវឌ្ឍធនធានមនុស្ស តាមរយៈការលើកកម្ពស់គុណភាពអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស ទាំងកម្រិតទាប មធ្យម និងខ្ពស់ ព្រមទាំងសុខុមាលភាពសង្គម ដើម្បីផ្គត់ផ្គង់ពលករជំនាញប្រកបដោយផលិតភាពខ្ពស់ ឱ្យបានគ្រប់គ្រាន់ទៅតាមតម្រូវការទីផ្សារ;
- ជំរុញការធ្វើពិពិធកម្មផលិតផល, គោលដៅ និងហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ និង
- បន្តជំរុញការអភិវឌ្ឍវិស័យកសិកម្ម ដោយផ្តោតលើការបង្កើនផលិតភាព, ពិពិធកម្ម, ការកែច្នៃកសិផល និងពាណិជ្ជូបនីយកម្ម ។

៣៨. ក្នុងន័យធានាឱ្យបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈក្នុងរយៈពេលមធ្យម, ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២១ បានគិតគូរដោយប្រុងប្រយ័ត្ន និងថ្លឹងថ្លែងរវាងទំហំតម្រូវការចំណាយដែលបន្តកើនឡើង ខណៈដែលការប្រមូលចំណូលមាននិន្នាការកំណើនទាបជាងកំណើនសក្តានុពលនាពេលកន្លងមក ។ ក្របខ័ណ្ឌគោបេនយោបាយហិរញ្ញវត្ថុសាធារណៈនេះ ក៏ត្រៀមលក្ខណៈរួចរាល់ ក្នុងការបន្តទ្រទ្រង់ប្រតិបត្តិការជាមូលដ្ឋាន និងជំរុញសកម្មភាពសេដ្ឋកិច្ចក្នុងបរិការណ៍ជំងឺកូវីដ-១៩, រក្សាលំនឹងជីវភាពរបស់ប្រជាពលរដ្ឋ តាមរយៈការបង្កើត និងរក្សាការងារ ព្រមទាំងបន្តជំរុញកំណើនសេដ្ឋកិច្ចឱ្យឆាប់ត្រឡប់ទៅរកកំណើនសក្តានុពលនាពេលមធ្យមខាងមុខ ។

៣៩. កំណើនចំណូលឆ្នាំ ២០២១ ត្រូវបានព្យាករថានឹងងើបឡើងវិញ តែលើមូលដ្ឋានចំណូលទាបក្នុងឆ្នាំ ២០២០ ដោយសារផលប៉ះពាល់នៃការរីករាលដាលជំងឺកូវីដ-១៩ គួបផ្សំនឹងការបន្តដាក់ចេញនូវវិធានការគោលនយោបាយអនុគ្រោះ ឬបន្ធូរបន្ថយពន្ធក្នុងករណីចាំបាច់បន្ថែម ព្រមជាមួយការសម្រួលនីតិវិធីរដ្ឋបាលសារពើពន្ធ

មួយចំនួន ក្នុងគោលដៅជំរុញសកម្មភាពអាជីវកម្ម និងធុរកិច្ចក្នុងស្រុក ។ សម្រាប់រយៈពេលខ្លី និងមធ្យមខាងមុខ, ការប្រមូលចំណូលអាចជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន ដូចជា÷ (១)- សន្ទុះកំណើនចំណូលសារពើពន្ធ អាចប្រឈមនឹងកំណើនយឺត ដោយសារការថមថយកំណើនសេដ្ឋកិច្ចជារួម, ការដាក់ចេញនូវការលើកទឹកចិត្តផ្នែកសារពើពន្ធ ដើម្បីជំរុញផលិតកម្មក្នុងស្រុក និងវិនិយោគផ្ទាល់ពីបរទេស, ការគាំទ្រការអភិវឌ្ឍវិស័យអាទិភាពផ្សេងៗ និងការអនុវត្តកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នាជាមួយប្រទេសដៃគូ ព្រមជាមួយការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាដើម ខណៈដែល (២)- ចំណូលមិនមែនសារពើពន្ធនៅមិនទាន់ប្រមូលឱ្យអស់សក្តានុពលនៅឡើយ ដោយសារភាពនៅមានកម្រិតនៃប្រសិទ្ធភាពក្នុងការគ្រប់គ្រង ក៏ដូចជាលទ្ធភាពក្នុងការប្រមូលចំណូលពីវិស័យសំខាន់ៗដែលនៅមានសក្តានុពលដូចជា វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍, វិស័យរ៉ែ និងថាមពល, កិច្ចសន្យាជួលទ្រព្យសម្បត្តិរដ្ឋ និងដីសម្បទានសេដ្ឋកិច្ចជាដើម និងជាពិសេសអវត្តមាននៃបទប្បញ្ញត្តិគោល, លិខិតបទដ្ឋានគតិយុត្តគាំទ្រ និងភាពមានកម្រិតនៃប្រព័ន្ធសម្រាប់គ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងទ្រព្យសម្បត្តិរដ្ឋ ។

៤០. ក្របខ័ណ្ឌចំណាយសាធារណៈឆ្នាំ ២០២១ ត្រូវបានរៀបចំដោយឈរលើគោលការណ៍បន្តលើកកម្ពស់ប្រសិទ្ធភាពចំណាយទាំងក្នុងកម្រិតវិភាជន៍ និងប្រតិបត្តិការ ព្រមទាំងរឹតបន្តឹងចំណាយមិនចាំបាច់ផ្សេងៗ ដើម្បីតម្រង់ទិសនៃការបែងចែក និងប្រើប្រាស់ធនធាន សំដៅធានាឱ្យបាននូវប្រក្រតីភាពនៃដំណើរការស្ថាប័នរដ្ឋ, បន្តអនុវត្តគោលនយោបាយគាំពារសង្គមជួយដល់ប្រជាជនក្រីក្រ និងជនងាយរងគ្រោះ, អនុវត្តកម្មវិធីសាច់ប្រាក់ពលកម្មជួយដល់អ្នកបាត់បង់ការងារ, បន្តផ្តល់អាទិភាពលើការពង្រឹងគុណភាព និងពង្រីកវិសាលភាពនៃការផ្តល់សេវាសាធារណៈ, បន្តវិនិយោគ លើហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាពខ្ពស់ និងពន្លឿនការតភ្ជាប់ក្នុងវិស័យដឹកជញ្ជូន, ថាមពល និងឌីជីថល ក្នុងន័យលើកកម្ពស់ភាពប្រកួតប្រជែង និងពិពិធកម្មសេដ្ឋកិច្ច ដើម្បីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ ។

៤១. ដើម្បីឈានទៅសម្រេចគោលបំណងនៃក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈខាងលើ, រាជរដ្ឋាភិបាលបានកំណត់គោលដៅសូចនាករហិរញ្ញវត្ថុសាធារណៈដូចខាងក្រោមនេះ÷

- ចំណូលក្នុងស្រុកសរុបសម្រាប់ឆ្នាំ ២០២១ ត្រូវបានគ្រោងប្រមាណ ១៨,៣៥% នៃ ផ.ស.ស ក្នុងនោះ ចំណូលចរន្តក្នុងទំហំ ១៨,១៧% នៃ ផ.ស.ស និងចំណូលមូលធនក្នុងស្រុកក្នុងទំហំ 0,១៩% នៃ ផ.ស.ស ។ ចំណូលចរន្តនឹងមានកំណើន ១៩,០% ធៀបនឹងការប៉ាន់ស្មានចំណូលចរន្តក្នុងឆ្នាំ ២០២០ (ឬ កំណើនអវិជ្ជមាន ១៨,០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២០) ដែលក្នុងនោះ ថ្នាក់ជាតិត្រូវសម្រេចឱ្យបានប្រមាណ ១៧,០៩% នៃ ផ.ស.ស និងសម្រាប់ថ្នាក់ក្រោមជាតិ ១,០៨% នៃ ផ.ស.ស ។ ជាមួយគ្នានេះ ការប្រមូលចំណូលពីអគ្គនាយកដ្ឋានពន្ធដារ ត្រូវគ្រោងសម្រេចឱ្យបាន ៧,៦៩% នៃ ផ.ស.ស, ចំណូលពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ត្រូវគ្រោងសម្រេចឱ្យបាន ៨,០៥% នៃ ផ.ស.ស និងចំណូលមិនមែនសារពើពន្ធត្រូវគ្រោងសម្រេចឱ្យបាន ២,៤២% នៃ ផ.ស.ស ។

- ចំណាយសរុបថវិការដ្ឋសម្រាប់ឆ្នាំ ២០២១ នឹងកំណត់ក្នុងរង្វង់ ២៥,០៧% នៃ ផ.ស.ស ក្នុងនោះ ចំណាយសរុបថវិកាថ្នាក់ជាតិ ២៣,៩៩% នៃ ផ.ស.ស និងចំណាយសរុបថវិកាថ្នាក់ក្រោមជាតិ ១,៩៤% នៃ ផ.ស.ស ដោយរួមបញ្ចូលទាំងការឧបត្ថម្ភធនដល់ថ្នាក់ក្រោមជាតិចំនួន ០,៨៦% នៃ ផ.ស.ស ។
    - ចំណាយចរន្តថវិការដ្ឋត្រូវកំណត់ក្នុងកម្រិត ១៥,៩៤% នៃ ផ.ស.ស ដែលក្នុងនោះ÷ ចំណាយបន្ទុកបុគ្គលិកមានសមាមាត្រស្មើនឹង ៤៨,៦% នៃចំណាយចរន្តថវិការដ្ឋ ត្រូវជា ៧,៧៥% នៃ ផ.ស.ស និង ចំណាយក្រៅបន្ទុកបុគ្គលិកមានសមាមាត្រស្មើនឹង ៥១,៤% ត្រូវជា ៨,១៩% នៃ ផ.ស.ស ។
    - ចំណាយមូលធនត្រូវបានគ្រោងក្នុងរង្វង់ ៩,១៣% នៃ ផ.ស.ស ក្នុងគោលដៅស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ, ជួយទ្រទ្រង់ផលិតភាពក្នុងសេដ្ឋកិច្ច និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ។ ក្នុងនោះ ចំណាយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស ត្រូវបានកំណត់ក្នុងរង្វង់ ៣,៤៩% នៃ ផ.ស.ស ដោយសារការបង្កើនមូលនិធិទ្រទ្រង់ថវិកា ខណៈដែលចំណាយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស ត្រូវបានគ្រោងក្នុងកម្រិត ៤,៦៣% នៃ ផ.ស.ស ។

៤២. ចំណាយថ្នាក់ជាតិ ដែលរួមបញ្ចូលទាំងហិរញ្ញប្បទានក្រៅប្រទេស ត្រូវបានគ្រោងវិភាជទៅតាមវិស័យដូចខាងក្រោម÷

- **វិស័យរដ្ឋបាលទូទៅ** ត្រូវបានគ្រោងប្រមាណ ១,៩៩% នៃ ផ.ស.ស សំដៅបន្តគាំទ្រការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ, ការកែទម្រង់ និងការលើកកម្ពស់សមត្ថភាពស្ថាប័ន ។

- **វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ** ត្រូវបានគ្រោងប្រមាណ ៣,៨៩% នៃ ផ.ស.ស ដែលនឹងបន្តផ្តោតការយកចិត្តទុកដាក់លើជីវភាព និងសុខុមាលភាពកងកម្លាំងប្រដាប់អាវុធ និងការបំពាក់មធ្យោបាយ និងបរិក្ខារចាំបាច់នានា ក្នុងបុព្វហេតុធានាកិច្ចការពារជាតិ និងរក្សាសន្តិភាព និងស្ថិរភាពនយោបាយ ។

- **វិស័យសង្គមកិច្ច** ត្រូវបានគ្រោងប្រមាណ ៦,១៤% នៃ ផ.ស.ស សំដៅបន្តគាំទ្រដល់ការលើកកម្ពស់គុណភាព និងពង្រីកការទទួលបានសេវាសុខាភិបាល ក៏ដូចជាសុខុមាលភាពសង្គម តាមរយៈការគាំទ្រដល់កម្មវិធីមូលនិធិសមធមិ និងការបន្តគាំទ្រដល់ការអនុវត្តគោលនយោបាយជាតិគាំពារសង្គម ជាពិសេសក្នុងបរិការណ៍ជំងឺកូវីដ-១៩ ។ ជាមួយគ្នានេះ បន្តការយកចិត្តទុកដាក់ខ្ពស់លើការអភិវឌ្ឍធនធានមនុស្ស តាមរយៈការលើកកម្ពស់គុណភាពអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសទាំងកម្រិតទាប មធ្យម និងខ្ពស់ ។

- **វិស័យសេដ្ឋកិច្ច** ត្រូវបានគ្រោងប្រមាណ ៦,៤២% នៃ ផ.ស.ស សំដៅបន្តធានាការអនុវត្តគោល-នយោបាយដើម្បីជំរុញកំណើន និងការបែងចែកផ្លែផ្កានៃកំណើនប្រកបដោយសមធមិក្នុងសង្គម ។ ក្នុងនោះ បន្តពន្លឿនការធ្វើពិពិធកម្មសេដ្ឋកិច្ច និងបង្កើនភាពប្រកួតប្រជែង ដោយផ្តោតលើការគាំទ្រការអភិវឌ្ឍវិស័យឯកជន និងការបន្តវិនិយោគសាធារណៈ លើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, ការតភ្ជាប់

ក្នុងវិស័យដឹកជញ្ជូន ថាមពល និងឌីជីថល ដើម្បីជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ ក្នុងបរិការណ៍វិបត្តិជំងឺកូវីដ-១៩ ។

- **ចំណាយផ្សេងៗ** ត្រូវបានគ្រោងក្នុងទំហំ ៥,៥៦% នៃ ផ.ស.ស សម្រាប់ឆ្នាំ ២០២១ ដើម្បីធានាបាននូវលទ្ធភាពក្នុងការដោះស្រាយនូវបញ្ហាសង្គម-សេដ្ឋកិច្ច ក៏ដូចជាត្រៀមបម្រុងសម្រាប់ការអនុវត្តគោល-នយោបាយនានា និងកិច្ចការបន្ទាន់ចំពោះមុខរបស់រាជរដ្ឋាភិបាល ក្នុងន័យឆ្លើយតបទៅនឹងផលប៉ះពាល់នៃវិបត្តិជំងឺកូវីដ-១៩ ។

**៤៣.** ដោយឈរលើមូលដ្ឋានក្របខ័ណ្ឌចំណូល និងចំណាយខាងលើ, **អតិរេកថវិកាចរន្ត** សម្រាប់ឆ្នាំ ២០២១ នឹងស្ថិតក្នុងអត្រា ២,២៣% នៃ ផ.ស.ស និង**ឱនភាពថវិកាសរុប** ស្ថិតក្នុងរង្វង់ ៦,៧២% នៃ ផ.ស.ស ។ *(សូមពិនិត្យក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០១៩-២០២៣ ក្នុងឧបសម្ព័ន្ធ២ ភ្ជាប់មកជាមួយ)*

**៤៤.** ដើម្បីធានាបាននូវការអនុវត្តទៅតាមគោលដៅខាងលើ និងដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ, ការគ្រោងថវិកាឆ្នាំ ២០២១ និងឆ្នាំបន្តបន្ទាប់ ត្រូវរៀបចំឡើងឈរលើមូលដ្ឋានយុទ្ធសាស្ត្រ និងក្របខ័ណ្ឌនៃវិធានការ ដូចខាងក្រោម÷

### ៤.១. វិធានការផ្នែកចំណូល

**៤៥.** វិធានការផ្នែកចំណូលសម្រាប់ឆ្នាំ ២០២១ ត្រូវបានរៀបចំដោយផ្អែកសំខាន់លើវិធានការប្រចាំឆ្នាំដែលបានកំណត់នៅក្នុង **យុទ្ធសាស្ត្រគៀរគរចំណូល ២០១៩-២០២៣** និងវិធានការជាក់លាក់បន្ថែម ដើម្បីគាំទ្រដល់ជីវភាពសេដ្ឋកិច្ច និងបន្តនិរន្តរភាពការងាររបស់រដ្ឋបាលប្រមូលចំណូលទាំងសារពើពន្ធ និងមិនមែនសារពើ-ពន្ធ ក្នុងបរិការណ៍វិបត្តិជំងឺកូវីដ-១៩ ។ វិធានការទាំងនោះ រួមមានដូចខាងក្រោម÷

#### ក. វិធានការផ្នែកពន្ធដារ

**៤៦.** វិធានការគន្លឹះ សម្រាប់អនុវត្តក្នុងឆ្នាំ ២០២១ ក្នុងទិសដៅរក្សាចីរភាពកំណើនចំណូលពន្ធដារ និងឆ្លើយតបនឹងបញ្ហាប្រឈមក្នុងបរិការណ៍ជំងឺកូវីដ-១៩ រួមមាន÷

- ***បន្តពង្រឹងមុខងារប្រតិបត្តិការស្នូល រួមមាន ការចុះបញ្ជីអ្នកជាប់ពន្ធ, ការផ្តល់សេវាអ្នកជាប់ពន្ធ, ការចាត់ចែងលិខិតប្រកាស, ការធ្វើសវនកម្ម, ការស៊ើបអង្កេត, ការប្រមូលបំណុលពន្ធ និងបណ្តឹងតវ៉ា÷***
  - បន្តកែលម្អប្រព័ន្ធគ្រប់គ្រងទិន្នន័យចុះបញ្ជីពន្ធដារ ដើម្បីសម្រួលដល់អ្នកជាប់ពន្ធក្នុងការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស និងរៀបចំយន្តការនៃការចុះបញ្ជីពន្ធដារតាមប្រព័ន្ធស្វ័យប្រវត្តិកម្មជាមួយក្រសួង-ស្ថាប័នផ្សេងៗ;
  - អនុវត្តការចុះបញ្ជីបែបអេឡិចត្រូនិក (e-registration), ការដាក់លិខិតប្រកាសពន្ធបែបអេឡិច-ត្រូនិក (e-filing), និងការបង់ប្រាក់ពន្ធបែបអេឡិចត្រូនិក (e-payment) ដែលមានលក្ខណៈស្វ័យប្រវត្តិកម្មពេញលេញ និងប្រទាក់ក្រឡា;

- ជំរុញការផ្តល់សេវាចុះបញ្ជីឱ្យបានទាន់ពេលវេលា ស្របតាមកម្រងសេវាសាធារណៈ និងសម្រេចគោលដៅនៃការចុះបញ្ជីឱ្យបាន ២០% ក្នុងមួយឆ្នាំ;
- ជំរុញការចុះបញ្ជីអចលនទ្រព្យនៅរាជធានីភ្នំពេញ ឱ្យបានពេញលេញតាមទិន្នន័យដែលបានអង្កេតក្នុងឆ្នាំ ២០២០ និងបញ្ចប់ការធ្វើបច្ចុប្បន្នភាពព័ត៌មានអចលនទ្រព្យនៅតាមបណ្តាខេត្តដែលមានសក្តានុពល ក្នុងឆ្នាំ ២០២១;
- បង្កើនការបញ្ជ្រាបវប្បធម៌នៃការបង់ពន្ធ, ច្បាប់, បទប្បញ្ញត្តិ និងកាតព្វកិច្ចពន្ធដារឱ្យកាន់តែទូលំទូលាយដល់សាធារណជន តាមរយៈការបង្កើនការផ្សព្វផ្សាយតាមបណ្តាញសារព័ត៌មាន, ការរៀបចំវគ្គបណ្តុះបណ្តាល, សិក្ខាសាលា និងវេទិកាពិគ្រោះយោបល់;
- ពង្រឹង និងពន្លឿនយន្តការបង្វិលសងអាករលើតម្លៃបន្ថែម តាមរយៈការបង្កើត និងដាក់ឱ្យអនុវត្តប្រព័ន្ធផ្ទៀងផ្ទាត់ដោយស្វ័យប្រវត្តិ និងបន្តធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់ e-filing និង e-payment;
- បន្តបង្កើនការប្រមូលទិន្នន័យព័ត៌មានពីគ្រប់ប្រភព និងបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអង្គភាពពាក់ព័ន្ធ តាមរយៈយន្តការផ្លាស់ប្តូរព័ត៌មាន ក្នុងគោលដៅកសាងកម្មវិធីសវនកម្មប្រចាំឆ្នាំ និងពង្រឹងការធ្វើសវនកម្មតាមវិស័យដែលមានហានិភ័យខ្ពស់;
- បង្កើតប្រព័ន្ធស្វ័យប្រវត្តិកម្មលើការកំណត់ហានិភ័យអ្នកជាប់ពន្ធ ដោយផ្អែកលើសៀវភៅណែនាំស្តីពីវិធីសាស្ត្រក្នុងការកំណត់ហានិភ័យអ្នកជាប់ពន្ធ និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធដើម្បីចាត់វិធានការលើបទល្មើសពន្ធដារ;
- ពង្រឹងការអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងបំណុលពន្ធ សំដៅកាត់បន្ថយជាអតិបរមានូវបំណុលបច្ចុប្បន្ន និងចៀសវាងការកើនឡើងបំណុលពន្ធអនាគត ជាពិសេសពង្រឹងការតឹងទារបំណុលចំពោះអាជីវកម្ម ដែលមិនទទួលរងផលប៉ះពាល់ពីជំងឺកូវីដ-១៩ និងអាជីវកម្មដែលមានសក្តានុពលតាមរយៈ ការរៀបចំកម្មវិធីលើកទឹកចិត្តឱ្យអ្នកជាប់ជំពាក់បំណុលមកបង់បានលឿនជាងកាលកំណត់ ឬបន្ធូរបន្ថយឱ្យបង់ជាដំណាក់កាល និង
- បន្តអនុវត្តវិធានការពាក់ព័ន្ធដែលបានដាក់ចេញ នៅក្នុងក្របខ័ណ្ឌគោលនយោបាយទំនើបកម្មប្រព័ន្ធពន្ធដារឆ្នាំ ២០១៩-២០២៣ ដែលផ្អែកលើគោលការណ៍អនុគ្រោះដល់កំណើន និងធានាយុត្តិធម៌, សមធម៌, សេវាល្អ, អភិបាលកិច្ចល្អ និងបង្កើនអនុលោមភាព ។

- *បន្តពង្រឹងមុខងារគាំទ្រ ÷*
  - គិតគូរដាក់ចេញនូវវិធានការគោលនយោបាយអនុគ្រោះ ឬបន្ធូរបន្ថយផ្នែកពន្ធដារ និងការសម្រួលនីតិវិធីរដ្ឋបាលសារពើពន្ធមួយចំនួន ដើម្បីជួយដល់អាជីវកម្ម និងធុរកិច្ចក្នុងស្រុកអាចបន្តដំណើរការ និងជួយដល់ការងើបឡើងវិញនៃសកម្មភាពសេដ្ឋកិច្ច;
  - បន្តកិច្ចការរៀបចំបទប្បញ្ញត្តិស្តីពីពន្ធដារ ដើម្បីសម្រួលដល់ការវិនិយោគ និងការប្រកបអាជីវកម្ម;

- ប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងការវិភាគទិន្នន័យ ដើម្បីបង្កើនសមត្ថភាពធ្វើសវនកម្ម សំដៅបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការគ្រប់គ្រងហានិភ័យ និង
- សិក្សា និងពិនិត្យលទ្ធភាព ដើម្បីឈានបង្កើតឱ្យមានមជ្ឈមណ្ឌលរក្សាទិន្នន័យរួម (big data) និងចូលរួមជាមួយស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធច្រកចេញចូលតែមួយនៃប្រព័ន្ធ National Internet Gateway និងប្រព័ន្ធទូទាត់ (payment gateway) ។

**ខ. វិធានការផ្នែកគយ**

៤៧. វិធានការគន្លឹះ ដែលគ្រោងនឹងដាក់ឱ្យអនុវត្តឆ្នាំ ២០២១ ដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា មាន ២ ផ្នែក និងផ្ដោតលើគោលដៅជាអាទិភាព ដូចខាងក្រោម÷

- ***បន្តពង្រឹងរដ្ឋបាលគយ និងកិច្ចសម្រួលពាណិជ្ជកម្ម÷***
  - បន្តកែលម្អប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ ដើម្បីជំរុញការអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ ដំណាក់កាលទី ៣, ប្រព័ន្ធគ្រប់គ្រងហានិភ័យគយ ដោយរៀបចំប្រព័ន្ធទទួលព័ត៌មានជាមុន និងអនុវត្តយន្តការសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ;
  - បន្តពង្រីកវិសាលភាព និងពង្រឹងប្រសិទ្ធភាពនៃការប្រើប្រាស់ប្រព័ន្ធត្រួតពិនិត្យដោយម៉ាស៊ីនស្កេន និងប្រព័ន្ធកាមេរ៉ាសុវត្ថិភាព;
  - បន្តអនុវត្តការសម្រួលការបញ្ចេញទំនិញពីគយសម្រាប់វត្ថុធាតុដើម និងផលិតផលនាំចេញ ក្នុងវិស័យដែលទទួលរងផលប៉ះពាល់ពីជំងឺកូវីដ-១៩ និងវិស័យអាទិភាពនានា;
  - កែសម្រួល និងដាក់ឱ្យអនុវត្តកញ្ចប់ប្រព្រឹត្តកម្មលើកទឹកចិត្តដល់ធុរជនដែលមានអនុលោមភាពខ្ពស់ តាមរយៈការផ្ដល់ប្រព្រឹត្តកម្មពិសេសក្នុងការបំពេញបែបបទគយ និងបន្តពិនិត្យលទ្ធភាពបង្កើនចំនួនធុរជនល្អបំផុត និង
  - បន្តពង្រឹងប្រសិទ្ធភាពការងារបច្ចេកទេសគយ (ការងារតម្លៃគិតពន្ធគយ, ការងារចំណាត់ថ្នាក់ទំនិញ និងការងារវិធានដើមកំណើតទំនិញ), ការអនុវត្តនីតិវិធីគយ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ។
- ***បន្តពង្រឹងគោលនយោបាយពន្ធគយ និងអភិបាលកិច្ច÷***
  - បន្តចូលរួមអនុវត្តគោលនយោបាយលើកទឹកចិត្តវិស័យអាទិភាព ដូចជា វិស័យកសិកម្ម, កម្មន្តសាល និងសហគ្រាសធុនតូច និងមធ្យម តាមរយៈ ១). ការពិនិត្យរកមុខទំនិញដើម្បីបញ្ចុះអត្រាពន្ធអាករនាំចូល និង ២). ការលើកសំណើទៅក្រុមការងារតារាងពន្ធគយអាស៊ាន (AHTN task force) ក្នុងការញែកលេខកូដចំពោះបន្ទាត់ពន្ធណាដែលមានមុខទំនិញបម្រើច្រើនវិស័យ ដើម្បីជាមូលដ្ឋាន អាចកំណត់អត្រាពន្ធគយខុសគ្នាឱ្យស្របតាមវិស័យនីមួយៗ;

- ពង្រឹងការអនុវត្តគោលការណ៍លើកទឹកចិត្តពន្ធ និងអាករសម្រាប់គ្រប់វិស័យ និងមុខសញ្ញាដែលទទួលបានការអនុគ្រោះ;
- បន្តធ្វើការវាយតម្លៃផលប៉ះពាល់លើកំណូលពន្ធគយ ដែលកោត់រេងំពី ១).ការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនានា, ២).ការកើនឡើងនូវផលិតផលក្នុងស្រុកជំនួសការនាំចូល និង ៣).ការអនុវត្តគោលនយោបាយទម្លាក់ថ្លៃអគ្គិសនី និងការប្រើប្រាស់ថាមពលពីប្រភពមិនមែនប្រេងឥន្ធនៈ;
- ពិនិត្យលទ្ធភាពកែសម្រួលមូលដ្ឋានគិតពន្ធ និងអត្រាអាករពិសេសលើទំនិញដែលមានលក្ខណៈប្រណិត, ប៉ះពាល់បរិស្ថាន និងសុខភាព ដើម្បីប៉ះប៉ូវការបាត់បង់ចំណូលតាមការចាំបាច់;
- បន្តអនុវត្តយុទ្ធសាស្ត្រគយស្តីពីអនុលោមភាព និងការអនុវត្តច្បាប់ (enforcement strategy) ក្នុងនោះរួមទាំងការចុះឃ្លាំមើលតំបន់ភូមិសាស្ត្រដែលមានហានិភ័យខ្ពស់, ការចែករំលែកព័ត៌មានពាក់ព័ន្ធបទល្មើសគយក្នុងកម្រិតទ្វេភាគី តំបន់ និងសកល, និងការចូលរួមគម្រោងប្រតិបត្តិការគយរួមគ្នា;
- បន្តលើកកម្ពស់អនុលោមភាព និងការអនុវត្តច្បាប់របស់ធុរជន តាមរយៈការផ្សព្វផ្សាយច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ ដើម្បីបង្កើនការយល់ដឹងអំពីតម្លៃនៃវប្បធម៌សារពើពន្ធស្ម័គ្រចិត្ត និងផលវិបាកនៃអំពើល្មើស និងអំពើរត់ពន្ធ និង
- រៀបចំផែនការជាក់លាក់ ក្នុងការរៀបចំធនធានមនុស្សតាមអង្គភាពនៅគ្រប់កម្រិត ដើម្បីឆ្លើយតបនឹងតម្រូវការ ក៏ដូចជាការត្រៀមខ្លួនសម្រាប់ការវិវត្តនៃបច្ចេកវិទ្យាថ្មី និងការឈានឆ្ពោះទៅសម្រេចបាននូវអង្គភាពមួយដែលទំនើប ។

## គ. វិធានការផ្នែកចំណូលមិនមែនសារពើពន្ធ

៤៨. ក្នុងទិសដៅបន្តពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងទ្រព្យសម្បត្តិរដ្ឋ និងបង្កើនចំណូលពីប្រភពដែលមានសក្តានុពល បន្ថែមលើវឌ្ឍនភាពសម្រេចបានកន្លងមក ក៏ដូចជាឆ្លើយតបនឹងបញ្ហាប្រឈមផ្សេងៗដែលអាចនឹងកើតមានឡើងក្នុងឆ្នាំ ២០២១ វិធានការគន្លឹះចាំបាច់ត្រូវបន្តអនុវត្ត រួមមាន÷

- ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់គ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) ឱ្យរីតតែទូលំទូលាយដល់រដ្ឋបាលថ្នាក់ក្រោមជាតិ, បន្តធ្វើបច្ចុប្បន្នភាព និងដាក់បញ្ចូលកិច្ចសន្យា កិច្ចព្រមព្រៀង ឬអាជ្ញាបណ្ណ និងបន្តជំរុញការតភ្ជាប់ និងសន្ទានកម្មរវាង NRMIS និង FMIS ឱ្យបានពេញលេញ;
- បន្តអភិវឌ្ឍមុខងារប្រព័ន្ធ NRMIS បន្ថែមដូចជាការផ្តល់វិក្កយបត្រតាមអនឡាញ និងការបង់ចំណូលមិនមែនសារពើពន្ធតាមរយៈការទូទាត់បែបអេឡិចត្រូនិក (e-payment) ដើម្បីលើកកម្ពស់ស្តង់ដារសេវាសម្រាប់បង់ចំណូលឱ្យមានភាពងាយស្រួល និងតម្លាភាព;

- បន្តពង្រឹងការអនុវត្តប្រព័ន្ធគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS) ក្នុងប្រព័ន្ធក្រៅបណ្តាញ (offline) ដោយជំរុញការរៀបចំបញ្ជីក្នុងប្រព័ន្ធ និងការរៀបចំប័ណ្ណកម្មសិទ្ធិឱ្យបានត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយ ដើម្បីឈានដល់ការតភ្ជាប់ប្រព័ន្ធ SARMIS ជាមួយប្រព័ន្ធគ្រប់គ្រងទិន្នន័យដទៃទៀត (online);
- លើកកម្ពស់សមត្ថភាពចរចាជាមួយភាគីពាក់ព័ន្ធ និងរៀបចំយន្តការគ្រប់គ្រងប្រភពចំណូលដែលមានសក្តានុពលក្នុងវិស័យរ៉ែ និងថាមពល ដូចជាចំណូលពីសម្បទាន និងចំណូលពីការបែងចែកផលឱ្យមានប្រសិទ្ធភាព;
- ជំរុញការសិក្សា និងពិនិត្យលទ្ធភាពអភិវឌ្ឍរមណីយដ្ឋានដែលមានសក្តានុពលថ្មីៗទាក់ទាញភ្ញៀវទេសចរ ដើម្បីបង្កើនទិសដៅទេសចរណ៍នៅកម្ពុជា;
- បន្តដកហូតមកវិញនូវហ្វ្រេកង់ដែលមិនប្រើប្រាស់ ដើម្បីដាក់ដេញថ្លៃឡើងវិញ, និងជំរុញការកែប្រែឡើងវិញនូវកម្រៃអាជ្ញាបណ្ណឱ្យបានសមស្រប និងគ្រប់ជ្រុងជ្រោយ តាមបទដ្ឋានជាធរមាន;
- បន្តជំរុញការប្រើប្រាស់ទិន្នន័យពីមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យទូរគមនាគមន៍ (DMC) ជាមូលដ្ឋានក្នុងការកំណត់ការបែងចែកប្រាក់ចំណូល និងសម្រាប់ផ្ទៀងផ្ទាត់ជាមួយចំណូលសារពើពន្ធ;
- បន្តជំរុញការអនុវត្តយន្តការតឹងទារបំណុលពិសេសក្នុងវិស័យទូរគមនាគមន៍;
- បន្តពង្រឹងការអនុវត្តប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាស្តីពីការគ្រប់គ្រងចំណូលពីកិច្ចសន្យាជួលកោះ, តំបន់ឆ្នេរ និងតំបន់រមណីយដ្ឋានឱ្យមានប្រសិទ្ធភាព និងជំរុញការអនុវត្តកាតព្វកិច្ចបង់ចំណូលតាមកិច្ចសន្យាជួលឱ្យបានពេញលេញ;
- ត្រៀមអនុវត្តគោលការណ៍រួម ស្របតាមតម្លៃទីផ្សារក្នុងការកៀរគរចំណូលពីការជួលទ្រព្យសម្បត្តិរដ្ឋ និងពន្លឿនកិច្ចការត្រួតពិនិត្យលើការអនុវត្តកិច្ចសន្យាជួលឱ្យបានរហ័ស;
- បន្តពន្លឿននីតិវិធីរៀបចំឡើងវិញនូវកិច្ចសន្យាដីសម្បទានសេដ្ឋកិច្ច និងពង្រឹងកិច្ចសហប្រតិបត្តិការរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធ ឱ្យកាន់តែមានប្រសិទ្ធភាព ខណៈបន្តការប្រមូលចំណូលពីដីសម្បទានសេដ្ឋកិច្ច ឱ្យអស់សក្តានុពលដោយផ្អែកលើគោលការណ៍ និងបទប្បញ្ញត្តិជាធរមាន;
- ដាក់ឱ្យប្រើប្រាស់ឯកសារគោល ស្តីពីការកែទម្រង់ប្រព័ន្ធចំណូលមិនមែនសារពើពន្ធ និងជំរុញការអនុម័តច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ និងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ;
- ដាក់ឱ្យអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាសម្រាប់ចាត់ចែងលើទ្រព្យសម្បត្តិ ដែលបានរឹបអូស;
- ពន្លឿនការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម និងរៀបចំលិខិតបទដ្ឋានគតិយុត្តនិងបទប្បញ្ញត្តិគាំទ្រ;

- បន្តរឹតត្បិតលើចំណាយមិនចាំបាច់ និងការមិនអនុញ្ញាតឱ្យក្រសួង-ស្ថាប័នណាមួយចាយលើសពីឥណទាន ដែលអនុញ្ញាតដោយច្បាប់ថវិកាប្រចាំឆ្នាំ;
- បន្តពង្រឹងការរៀបចំស្តង់ដារប្រព័ន្ធគណនេយ្យសាធារណៈ និងការធ្វើអធិការកិច្ចហិរញ្ញវត្ថុ ព្រមទាំងលើកកម្ពស់ការអនុវត្តវិធានការរដ្ឋបាល និងវិន័យហិរញ្ញវត្ថុតាមច្បាប់ជាធរមាន;
- បន្តពង្រឹងការអនុវត្តផែនការសកម្មភាពរបស់គោលនយោបាយ និងកម្មវិធីកែទម្រង់ ក្នុងវិស័យសំខាន់ៗ រួមមាន÷ ក).កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ខ).យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ២០១៨-២០២៥, គ).យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥, ឃ).យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩-២០២៣, ង).យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ២០១៩-២០២៥ និង ច).យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០១៩-២០២៥;
- ជំរុញការអនុវត្តកម្មវិធីសហហិរញ្ញប្បទាន (co-financing) និងចែករំលែកហានិភ័យ (risk sharing) ជាមួយវិស័យឯកជន និងកម្មវិធីធានាឥណទាន (credit guarantee);
- អនុវត្តអនុក្រឹត្យ ស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈ ឱ្យមានប្រសិទ្ធភាពខ្ពស់;
- រៀបចំគោលការណ៍ និងនីតិវិធីគ្រប់គ្រងការប្រើប្រាស់ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងជំរុញប្រសិទ្ធភាពនៃការរៀបចំផែនការនៃការថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ជាពិសេសការគិតគូរ និងឈានទៅផ្សារភ្ជាប់រវាងគម្រោងស្ថាបនា និងជួសជុល និងគម្រោងថែទាំហេដ្ឋារចនាសម្ព័ន្ធឱ្យបានទាន់ពេលវេលា;
- បន្តអនុវត្តក្របខ័ណ្ឌគោលនយោបាយស្តីពីការគ្រប់គ្រងបំណុលសាធារណៈ របស់រាជរដ្ឋាភិបាល ដោយបន្តគោរពតាមគោលការណ៍គន្លឹះ ទាំងទំហំ និងកម្រិតពិដាន ដើម្បីចូលរួមជំរុញការតភ្ជាប់, និងលើកកម្ពស់សមត្ថភាពប្រកួតប្រជែង ក្នុងវិស័យអាទិភាពរបស់រាជរដ្ឋាភិបាល ។ លើសពីនេះបន្តពង្រឹងប្រសិទ្ធភាពចំណាយវិនិយោគសាធារណៈ ទាំងក្នុងក្របខ័ណ្ឌហិរញ្ញប្បទានដោយថវិកាជាតិ, ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ និងយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន តាមរយៈ÷ ១).ការអនុវត្តប្រកាស ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធី និងបែបបទអនុវត្តចំណាយវិនិយោគសាធារណៈហិរញ្ញប្បទានដោយថវិកាថ្នាក់ជាតិ ឱ្យកាន់តែមានភាពច្បាស់លាស់គ្រប់ដំណាក់កាល, ២).ការធ្វើបច្ចុប្បន្នកម្មនីតិវិធីរួមសម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍ និង ៣).ការរៀបចំបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន;
- បន្តអនុវត្តវិធានការគន្លឹះ ក្នុងទិសដៅពង្រឹងប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការអនុវត្តចំណាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន÷

- ពន្លឿនការរៀបចំនូវក្របខ័ណ្ឌគតិយុត្តថ្មីស្តីពីការគ្រប់គ្រងសហគ្រាសសាធារណៈ ឱ្យស្របតាមការវិវឌ្ឍនៃសកម្មភាពសេដ្ឋកិច្ចកម្ពុជាជាក់ស្តែង;
- បង្កើនកិច្ចសហការរវាងថ្នាក់ដឹកនាំ និងមន្ត្រីបង្គោលតាមក្រសួង-ស្ថាប័ន ដែលទទួលខុសត្រូវអនុវត្តផែនការសកម្មភាពនៃយុទ្ធសាស្ត្រប្រមូលចំណូល ដោយតាមដាន និងរាយការណ៍ជាប្រចាំ និង
- ពង្រឹងប្រសិទ្ធភាព នៃដំណើរការរបស់គណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលមិនមែនសារពើពន្ធ ដើម្បីធ្វើការតាមដាន និងរៀបចំរបាយការណ៍បូកសរុបជូនប្រមុខរាជរដ្ឋាភិបាលស្តីពីស្ថានភាពនៃការប្រមូលចំណូលរបស់ក្រសួង-ស្ថាប័ននៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

### ៤.២ វិធានការផ្នែកចំណាយ

៤៩. ក្នុងក្របខ័ណ្ឌនៃគោលដៅរក្សាលំនឹងសេដ្ឋកិច្ច និងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ ក្នុងបរិការណ៍កូវីដ-១៩, រាជរដ្ឋាភិបាល នឹងអនុវត្តវិធានការជាក់លាក់ និងមុតស្រួច ដើម្បីបង្កើនប្រសិទ្ធភាពចំណាយក្នុងឆ្នាំ ២០២១ ដូចខាងក្រោម÷

- ត្រៀមកញ្ចប់ថវិកាសម្រាប់ដោះស្រាយតម្រូវការបន្ទាន់ និងចាំបាច់ភ្លាមៗ ក្នុងវិបត្តិជំងឺកូវីដ-១៩ ដើម្បីទ្រទ្រង់សកម្មភាពសេដ្ឋកិច្ច និងជួយគាំទ្រទាន់ពេលវេលាលើកម្មវិធីសំណាញ់សុវត្ថិភាពដល់ក្រុមអ្នកងាយរងគ្រោះ និងរក្សាលំនឹងការងារជូនប្រជាពលរដ្ឋដែលប៉ះពាល់ពីវិបត្តិនេះ;
- រក្សាកម្រិតប្រាក់បៀវត្សក្នុងឆ្នាំ ២០២១ របស់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ឱ្យស្មើនឹងកម្រិតដែលទទួលបានក្នុងឆ្នាំ ២០២០ ។ លើសពីនេះ គ្រប់ក្រសួង-ស្ថាប័នទាំងអស់ត្រូវអនុវត្តឱ្យខ្ជាប់ខ្ជួនដាច់ខាតនូវគោលការណ៍ជាធរមាន ក្នុងការជ្រើសរើសក្របខ័ណ្ឌមន្ត្រីថ្មី ឱ្យស្មើនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍;
- បន្តកែលម្អគុណភាព និងភាពគ្រប់ជ្រុងជ្រោយនៃផែនការយុទ្ធសាស្ត្រថវិកា ដោយពង្រឹងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយតាមវិស័យអាទិភាព;
- បន្តពង្រឹងការផ្សារភ្ជាប់ផែនការលទ្ធកម្មជាមួយនឹងសំណើថវិកាប្រចាំឆ្នាំ;
- បន្តអភិវឌ្ឍសមត្ថភាពមន្ត្រីជំនាញពាក់ព័ន្ធ និងធនធានមនុស្ស;
- បន្តពង្រឹងការអនុវត្តថវិកាកម្មវិធីនៅគ្រប់ក្រសួង-ស្ថាប័ន (រួមបញ្ចូលរដ្ឋបាលរាជធានី-ខេត្ត) និងពង្រឹងគុណភាពព័ត៌មានសមិទ្ធកម្ម ដើម្បីឈានទៅចាប់ផ្តើមអនុវត្តថវិកាសមិទ្ធកម្ម តាមរយៈការអនុវត្តកិច្ចព្រមព្រៀងលើលទ្ធផលក្នុងឆ្នាំ និងការរៀបចំយន្តការសម្រាប់ធ្វើការវាយតម្លៃ និងការផ្តល់ព័ត៌មានពីសមិទ្ធកម្ម និងនីតិវិធីការងារសវនកម្មសមិទ្ធកម្មទៅក្នុងក្របខ័ណ្ឌសវនកម្មផ្ទៃក្នុង;
- ពង្រឹង និងពង្រីកការអនុវត្តប្រព័ន្ធ FMIS ដល់គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយចាប់ផ្តើមអនុវត្តស្វ័យប្រវត្តិកម្មចំណាយ និងដាក់ចំណាត់ថ្នាក់ថវិកាទាំង ៧;

- អនុវត្តផែនការសកម្មភាពលម្អិត នៃយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០១៩-២០២៥;
- ពិនិត្យឡើងវិញនូវការអនុវត្តថវិកាការផ្ទេរមុខងាររបស់ក្រសួង-ស្ថាប័ន ដើម្បីរៀបចំជារបាយការណ៍របកគំហើញ ដាក់ជូនថ្នាក់ដឹកនាំពិនិត្យ និងផ្តល់អនុសាសន៍;
- បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលឃុំ-សង្កាត់ តាមរយៈការសិក្សាកែ-សម្រួលនីតិវិធីលទ្ធកម្មឃុំ-សង្កាត់;
- ពង្រឹងគុណភាព និងភាពគ្រប់ជ្រុងជ្រោយនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិការដ្ឋបាលថ្នាក់ក្រោមជាតិ (រដ្ឋបាលរាជធានី-ខេត្ត) ឱ្យបានទាន់ពេលវេលា ដើម្បីជាមូលដ្ឋានក្នុងការរៀបចំផែនការ និងគម្រោងថវិកាប្រចាំឆ្នាំ;
- ដាក់ឱ្យរដ្ឋបាលរាជធានី-ខេត្ត ទាំង ២៥ អនុវត្តថវិកាកម្មវិធី ដើម្បីធានាបាននូវការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ព្រមទាំងលើកកម្ពស់ប្រសិទ្ធភាពនៃការវិភាជថវិកាឱ្យចំគោលដៅអាទិភាព និងប្រសិទ្ធភាពនៃការអនុវត្តថវិកា;
- ជំរុញការរៀបចំសៀវភៅថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច និងចំណាត់ថ្នាក់កម្មវិធីឱ្យបានទាន់ពេលវេលា ដើម្បីបញ្ចូលក្នុងប្រព័ន្ធ FMIS និង
- ពិនិត្យយន្តការគ្រប់គ្រងថវិការដ្ឋបាលក្រុង ស្រុក និងខណ្ឌ ក្រោយការធ្វើសមាហរណកម្មការិយាល័យមន្ទីរជំនាញ ទៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ ។

## ៥. សេចក្តីសន្និដ្ឋាន

៥០. ក្នុងរយៈពេលមធ្យម ហានិភ័យចំពោះសេដ្ឋកិច្ចកម្ពុជានឹងមានទំហំធំជាងពេលណាៗទាំងអស់ ដោយសារភាពមិនប្រាកដប្រជានៃការអូសបន្លាយការរីករាលដាលជំងឺកូវីដ-១៩ ដែលធ្វើឱ្យបរិការណ៍សេដ្ឋកិច្ចសកលមានការផ្លាស់ប្តូរជារចនាសម្ព័ន្ធ ស្របពេលដែលកម្ពុជាពឹងផ្អែកខ្លាំងលើតម្រូវការខាងក្រៅ ។ ជាមួយគ្នានេះផងដែរ សេដ្ឋកិច្ចកម្ពុជានៅតែអាស្រ័យលើមូលដ្ឋានតូច ហើយល្បឿននៃការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការធ្វើឱ្យប្រសើរនូវភាពងាយស្រួលក្នុងការធ្វើធុរកិច្ចនៅមានភាពយឺតយ៉ាវ ដែលបញ្ហាទាំងនេះជាកត្តារាំងស្ទះជាចម្បងដល់ការងើបឡើងវិញនៃកំណើនសេដ្ឋកិច្ចក្នុងបរិការណ៍វិបត្តិជំងឺកូវីដ-១៩ ។ ក្នុងន័យនេះ កម្ពុជានឹងបង្កើនការប្តេជ្ញាចិត្ត និងធនធាន និងតម្រង់កិច្ចខិតខំប្រឹងប្រែង ដើម្បីប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩, សម្រួលបរិយាកាសធុរកិច្ច និងលើកកម្ពស់ការធ្វើពិពិធកម្មសេដ្ឋកិច្ចឱ្យបានជាអតិបរមា ជាពិសេសឆ្លើយតបឱ្យបានទាន់ពេលវេលាទៅនឹងការវិវត្តនៃព្រឹត្តិការណ៍ក្នុងតំបន់ និងសកល និងការប្រែប្រួលនានា ។

**៥១.** ជារួម ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២១ ត្រូវបានរៀបចំឡើងក្នុងបរិបទនៃការគិតគូររក្សាលំនឹងសេដ្ឋកិច្ច និងជំរុញកំណើនសេដ្ឋកិច្ច ព្រមទាំងធានាឱ្យបាននូវការបង្កើត និងរក្សាការងារជូនប្រជាពលរដ្ឋ ។ ជាក់ស្តែង ក្របខ័ណ្ឌនេះមានគោលដៅគាំទ្រការ

ជំរុញកំណើនសេដ្ឋកិច្ចឱ្យសម្រេចបានក្នុងរង្វង់ ៣,៥% ជាមួយនឹងអត្រាអតិផរណាទាបដែលអាចគ្រប់គ្រងបានក្នុងរង្វង់ ៣% និងស្ថិរភាពអត្រាប្តូរប្រាក់ក្នុងរង្វង់ ៤ ១០០ រៀល ក្នុងមួយដុល្លារអាមេរិក ។ ជាមួយគ្នានេះ ដើម្បីសម្រេចបានគោលបំណងខាងលើ រាជរដ្ឋាភិបាលនឹងបង្កើនប្រសិទ្ធភាពនៃការអនុវត្តវិធានការគោលនយោបាយនានា ជាពិសេសតាមរយៈការពង្រឹងសបត្ថភាព និងការសម្របសម្រួលស្ថាប័នឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ។

**[ចប់]**

## ឧបសម្ព័ន្ធ ១៖ ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច ២០១៧-២០២៣

| សូចនាករ | 2017 | 2018 | 2019 ប. | 2020 ប. | 2021 ព្យ. | 2022 ព្យ. | 2023 ព្យ. |
|---|---|---|---|---|---|---|---|
| ផសស ថ្លៃបច្ចុប្បន្ន (ប៊ីលានរៀល) | **89,831** | **99,544** | **110,014** | **110,653** | **117,939** | **127,198** | **138,857** |
| ផសស សម្រាប់ម្នាក់ (ដុល្លារ) | 1,430 | 1,563 | 1,700 | 1,683 | 1,771 | 1,887 | 2,035 |
| កំណើន ផសស ពិត (%) | **7.0%** | **7.5%** | **7.1%** | **-1.9%** | **3.5%** | **5.0%** | **6.5%** |
| អត្រាបរិវត្តិផរណា ផសស (កំណើនប្រចាំឆ្នាំ) | 3.3% | 3.1% | 3.2% | 2.6% | 3.0% | 2.7% | 2.5% |
| អត្រាអតិផរណា (កំណើនជាមធ្យមប្រចាំឆ្នាំ) | 2.9% | 2.5% | 1.8% | 2.8% | 3.1% | 3.0% | 3.0% |
| អត្រាប្តូរប្រាក់ (រៀល/ដុល្លារ) | 4,045 | 4,045 | 4,055 | 4,065 | 4,065 | 4,065 | 4,065 |
| ការនាំចេញ (%នៃ ផសស) | 50.5% | 52.7% | 55.2% | 49.9% | 49.4% | 50.1% | 51.0% |
| ការនាំចូល (%នៃ ផសស) | 69.8% | 76.4% | 82.0% | 78.3% | 77.9% | 78.1% | 78.4% |
| សមតុល្យពាណិជ្ជកម្ម (%នៃ ផសស) | -19.3% | -23.7% | -26.7% | -28.4% | -28.5% | -28.0% | -27.5% |
| សមតុល្យគណនីចរន្ត (រួមបញ្ចូលបង្វែរ) (%នៃ ផសស) | -8.1% | -12.2% | -15.5% | -17.6% | -17.3% | -16.6% | -16.1% |
| ទុនបម្រុងអន្តរជាតិ (លានដុល្លារ) | 12,201 | 14,629 | 18,763 | 16,937 | 16,981 | 17,178 | 17,585 |
| ចំនួនខែនៃការនាំចូល | 8.0 | 8.0 | 8.8 | 8.5 | 8.0 | 7.5 | 7.0 |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា (វិស័យខាងក្រៅឆ្នាំ ២០១៩ ត្រីមាសទី ៣) និងការព្យាកររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ឧបសម្ព័ន្ធ ២៖ ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ

### ក. ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ: ២០១៩-២០២១

*ផសស តាមថ្លៃចរន្តឆ្នាំ ២០១៨ (ប៉ាន់ស្មាន)* 99,544

*ផសស តាមថ្លៃចរន្តឆ្នាំ ២០១៩ (គម្រោង)* 110,014

*ផសស តាមថ្លៃចរន្តឆ្នាំ ២០២០ (គម្រោង)* 110,653

*ផសស តាមថ្លៃចរន្តឆ្នាំ ២០២១ (គម្រោង)* 117,939

*ឯកតា៖ ប៊ីលានរៀល*

| ចំណូល- ចំណាយ | ២០១៩ | | | | | ២០២០ | | | | ២០២១ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ច្បាប់ ហិ | បណ្តោះ អាសន្ន (*) | % ច្បាប់ | % អនុ. ២០១៧ | % ផសស | ច្បាប់ ហិ | កែតម្រូវ | ប្រែប្រួល កែ./ច្ប. | កែ. ព្យ % ផសស | គម្រោង | % កែ២០២០ | % ច្បាប់ ២០២០ | % ផសស |
| **ចំណូលក្នុងប្រទេសសរុប** | **21,186** | **27,743** | **130.9%** | **130.9%** | **25.22%** | **26,336** | **18,203** | **69.1%** | **16.45%** | **21,647** | **118.9%** | **82.2%** | **18.35%** |
| ចំណូលចរន្ត | 20,993 | 27,561 | 131.3% | 131.3% | 25.05% | 26,143 | 18,010 | 68.9% | 16.28% | 21,426 | 119.0% | 82.0% | 18.17% |
| ចំណូលមូលធន | 193 | 181 | 93.9% | 93.9% | 0.16% | 193 | 193 | 100.0% | 0.17% | 221 | 114.4% | 114.4% | 0.19% |
| រដ្ឋបាល កណ្តាល | | | | | | | | | | | | | |
| *ចំណូលចរន្ត* | *19,593* | *25,396* | *129.6%* | *129.6%* | *23.08%* | *23,899* | *16,894* | *70.7%* | *15.27%* | *20,154* | *119.3%* | *84.3%* | *17.09%* |
| ចំណូលសារពើពន្ធ | 16,879 | 22,054 | 130.7% | 130.7% | 20.05% | 21,091 | 14,912 | 70.7% | 13.48% | 17,519 | 117.5% | 83.1% | 14.85% |
| ចំណូលមិនមែនសារពើពន្ធ | 2,714 | 3,342 | 123.1% | 123.1% | 3.04% | 2,808 | 1,982 | 70.6% | 1.79% | 2,635 | 132.9% | 93.8% | 2.23% |
| *ចំណូលមូលធន* | *193* | *181* | *93.9%* | *93.9%* | *0.16%* | *193* | *193* | *100.0%* | *0.17%* | *221* | *114.4%* | *114.4%* | *0.19%* |
| រាជធានី-ខេត្ត | 1,400 | 2,165 | 154.7% | 154.7% | 1.97% | 2,244 | 1,116 | 49.7% | 1.01% | 1,271 | 113.9% | 56.7% | 1.08% |
| ចំណូលសារពើពន្ធ | 1,352 | 2,105 | 155.7% | 155.7% | 1.91% | 2,086 | 1,014 | 48.6% | 0.92% | 1,050 | 103.6% | 50.3% | 0.89% |
| ចំណូលមិនមែនសារពើពន្ធ | 48 | 61 | 125.4% | 125.4% | 0.06% | 157 | 102 | 65.0% | 0.09% | 221 | 216.0% | 140.4% | 0.19% |
| ចំណូលតាមអង្គភាព | | | | | | | | | | | | | |
| អគ្គនាយកដ្ឋានពន្ធដារ | 9,137 | 11,261 | 123.3% | 123.3% | 10.24% | 11,531 | 7,879 | 68.3% | 7.12% | 9,074 | 115.2% | 78.7% | 7.69% |
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករ | 9,094 | 12,897 | 141.8% | 141.8% | 11.72% | 11,646 | 8,047 | 69.1% | 7.27% | 9,496 | 118.0% | 81.5% | 8.05% |
| អគ្គនាយកដ្ឋានចំណូលផ្សេងៗ | 2,762 | 3,402 | 123.2% | 123.2% | 3.09% | 2,966 | 2,085 | 70.3% | 1.88% | 2,856 | 137.0% | 96.3% | 2.42% |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **ចំណាយសរុប** | 27,165 | 28,329 | 104.3% | 104.3% | 25.75% | 33,340 | 29,322 | 88.0% | 26.50% | 29,570 | 100.8% | 88.7% | 25.07% |
| ចំណាយចរន្ត | 17,908 | 18,544 | 103.6% | 103.6% | 16.86% | 19,818 | 18,117 | 91.4% | 16.37% | 18,799 | 103.8% | 94.9% | 15.94% |
| ចំណាយមូលធន | 9,257 | 9,785 | 105.7% | 105.7% | 8.89% | 13,521 | 11,205 | 82.9% | 10.13% | 10,771 | 96.1% | 79.7% | 9.13% |
| រដ្ឋបាលកណ្តាល | | | | | | | | | | | | | |
| *ចំណាយចរន្ត* | *16,827* | *17,090* | *101.6%* | *101.6%* | *15.53%* | *18,037* | *17,285* | *95.8%* | *15.62%* | *17,781* | *102.9%* | *98.6%* | *15.08%* |
| *ចំណាយមូលធន* | *8,032* | *8,581* | *106.8%* | *106.8%* | *7.80%* | *11,953* | *9,816* | *82.1%* | *8.87%* | *9,332* | *95.1%* | *78.1%* | *7.91%* |
| -ដោយហិរញ្ញប្បទានក្នុងប្រទេស | 2,708 | 3,524 | 130.1% | 130.1% | 3.20% | 5,900 | 3,763 | 63.8% | 3.40% | 3,866 | 102.8% | 65.5% | 3.28% |
| -ដោយហិរញ្ញប្បទានក្រៅប្រទេស | 5,324 | 5,058 | 95.0% | 95.0% | 4.60% | 6,053 | 6,053 | 100.0% | 5.47% | 5,466 | 90.3% | 90.3% | 4.63% |
| រាជធានីខេត្ត | | | | | | | | | | | | | |
| ចំណាយចរន្ត | 1,880 | 3,227 | 171.6% | 171.6% | 2.93% | 2,867 | 1,771 | 61.8% | 1.60% | 2,028 | 114.5% | 70.7% | 1.72% |
| ចំណាយមូលធន | 320 | 320 | 100.0% | 100.0% | 0.29% | 462 | 283 | 61.3% | 0.26% | 254 | 89.7% | 55.0% | 0.22% |
| *ឧបត្ថម្ភធនរាជធានី-ខេត្ត* | *800* | *1,773* | *221.7%* | *221.7%* | *1.61%* | *1,085* | *939* | *86.5%* | *0.85%* | *1,011* | *107.7%* | *93.2%* | *0.86%* |
| **តុល្យភាព** | | | | | | | | | | | | | |
| អតិរេកថវិកាចរន្ត | 3,086 | 9,018 | 292.3% | 292.3% | 8.20% | 6,325 | (107) | -1.7% | -0.10% | 2,627 | -2447.8% | 41.5% | 2.23% |
| ឱនភាពសរុប | (5,979) | (586) | 9.8% | 9.8% | -0.53% | (7,003) | (12,780) | 182.5% | -11.55% | (7,923) | 62.0% | 113.1% | -6.72% |
| **ហិរញ្ញប្បទាននៃឱនភាព** | 5,979 | 586 | 9.8% | 9.8% | 0.53% | 7,003 | 12,780 | 182.5% | 11.55% | 7,923 | 62.0% | 113.1% | 6.72% |
| ក្នុងប្រទេស | (501) | (5,893) | 1176.4% | 1176.4% | -5.36% | (406) | 5,371 | -1323.0% | 4.85% | 415 | 7.7% | -102.2% | 0.35% |
| ក្រៅប្រទេស | 6,480 | 6,480 | 100.0% | 100.0% | 5.89% | 7,409 | 7,409 | 100.0% | 6.70% | 7,508 | 101.3% | 101.3% | 6.37% |
| ទ្រទ្រង់ថវិកាដោយដៃគូអភិវឌ្ឍន៍ | 250 | 250 | 100.0% | 100.0% | 0.23% | 250 | 250 | 100.0% | 0.23% | 858 | 343.0% | 343.0% | 0.73% |
| មូលធនក្រៅប្រទេស | 5,324 | 5,324 | 100.0% | 100.0% | 4.84% | 6,053 | 6,053 | 100.0% | 5.47% | 5,466 | 90.3% | 90.3% | 4.63% |
| ការទូទាត់ប្រាក់កម្ចី | 906 | 906 | 100.0% | 100.0% | 0.82% | 1,106 | 1,106 | 100.0% | 1.00% | 1,185 | 107.2% | 107.2% | 1.00% |

*(*) សម្គាល់៖ តួលេខបណ្តោះអាសន្នគិតត្រឹមថ្ងៃ ១៨ ខុសភា ឆ្នាំ ២០២០*

## ខ. ក្របខ័ណ្ឌចំណូល-ចំណាយរយៈពេលមធ្យម ២០១៩-២០២៣

| ចំណូល/ចំណាយ | 2019 បណ្តោះ. | 2020 ច្បាប់ | 2020 កែតម្រូវ | 2021 ព្យ. | 2022 ព្យ. | 2023 ព្យ. |
|---|---|---|---|---|---|---|
| *ចំណាយបន្ទុកបុគ្គលិកជា % នៃ ចំណាយចរន្តសរុប* | *45.9%* | *46.1%* | *50.4%* | *48.6%* | *47.3%* | *53.1%* |
| **ប៊ីលានរៀល** | | | | | | |
| I. ចំណូលក្នុងស្រុក | 27,743 | 26,336 | 18,203 | 21,647 | 24,807 | 28,339 |
| *I.1 ចំណូលចរន្តសរុប* | *27,561* | *26,143* | *18,010* | *21,426* | *24,569* | *28,060* |
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករ | 12,897 | 11,646 | 8,047 | 9,496 | 10,508 | 11,766 |
| អគ្គនាយកដ្ឋានពន្ធដារ | 11,261 | 11,531 | 7,879 | 9,074 | 10,777 | 12,502 |
| ចំណូលមិនមែនសារពើពន្ធសរុប | 3,402 | 2,966 | 2,085 | 2,856 | 3,284 | 3,791 |
| *ក្នុងនោះ ចំណូលពន្ធផ្សេងៗ* | *308* | *322* | *259* | *259* | *229* | *268* |
| II. ចំណាយសរុប | 28,329 | 33,340 | 29,322 | 29,570 | 31,177 | 35,599 |
| *II.1 ចំណាយចរន្តសរុប* | *18,544* | *19,818* | *18,117* | *18,799* | *19,322* | *22,981* |
| បន្ទុកបុគ្គលិក | 8,517 | 9,139 | 9,139 | 9,139 | 9,139 | 12,200 |
| បន្ទុកមិនមែនបុគ្គលិក | 10,026 | 10,679 | 8,978 | 9,660 | 10,183 | 10,781 |
| *II.2 ចំណាយមូលធនសរុប* | *9,785* | *13,521* | *11,205* | *10,771* | *11,855* | *12,618* |
| ហិរញ្ញប្បទានក្នុងប្រទេសសរុប | 3,843 | 6,362 | 4,046 | 6,362 | 4,121 | 4,313 |
| ទូទាត់ការខ្ចី | 884 | 1,106 | 1,106 | 1,106 | 1,185 | 1,422 |
| ហិរញ្ញប្បទានក្រៅប្រទេស | 5,058 | 6,053 | 6,053 | 6,053 | 5,466 | 6,120 |
| III. អតិរេកចរន្ត | 9,018 | 6,325 | -107 | 2,627 | 5,247 | 5,078 |
| IV. និនភាព/អតិរេកសរុប | -586 | -7,003 | -12,780 | -7,923 | -6,370 | -7,259 |
| **កំណើនប្រចាំឆ្នាំ** | 2019 ប. /2018 អនុវត្ត | 2020 ច្ប. /2019 ប. | 2020 កែ. /2019 ប. | 2021 ព្យ. /2020 កែ | 2022 ព្យ. /2021 ព្យ. | 2023 ព្យ. /2022 ព្យ. |
| I. ចំណូលក្នុងស្រុក | 26.2% | -5.1% | -34.4% | 18.9% | 14.6% | 14.2% |
| *I.1 ចំណូលចរន្តសរុប* | *26.5%* | *-5.1%* | *-34.7%* | *19.0%* | *14.7%* | *14.2%* |
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករ | 27.7% | -9.7% | -37.6% | 18.0% | 10.7% | 12.0% |
| អគ្គនាយកដ្ឋានពន្ធដារ | 28.3% | 2.4% | -30.0% | 15.2% | 18.8% | 16.0% |
| ចំណូលមិនមែនសារពើពន្ធសរុប | 17.3% | -12.8% | -38.7% | 37.0% | 15.0% | 15.4% |
| II. ចំណាយសរុប | 4.3% | 17.7% | 3.5% | 0.8% | 5.4% | 14.2% |
| *II.1 ចំណាយចរន្តសរុប* | *3.6%* | *6.9%* | *-2.3%* | *3.8%* | *2.8%* | *18.9%* |
| បន្ទុកបុគ្គលិក | 2.2% | 7.3% | 7.3% | 0.0% | 0.0% | 33.5% |
| បន្ទុកមិនមែនបុគ្គលិក | 4.7% | 6.5% | -10.4% | 7.6% | 5.4% | 5.9% |
| *II.2 ចំណាយមូលធនសរុប* | *5.7%* | *38.2%* | *14.5%* | *-3.9%* | *10.1%* | *6.4%* |
| ហិរញ្ញប្បទានក្នុងប្រទេសសរុប | 26.9% | 65.5% | 5.3% | 57.2% | -35.2% | 4.7% |
| ទូទាត់ការខ្ចី | -2.4% | 25.0% | 25.0% | 0.0% | 7.2% | 20.0% |
| ហិរញ្ញប្បទានក្រៅប្រទេស | -5.0% | 19.7% | 19.7% | 0.0% | -9.7% | 12.0% |
| **ផលធៀបនឹង ផ.ស.ស** | 2019 បណ្តោះ. | 2020 ច្បាប់ | 2020 កែតម្រូវ | 2021 ព្យ. | 2022 ព្យ. | 2023 ព្យ. |
| I. ចំណូលក្នុងស្រុក | 25.22% | 23.80% | 16.45% | 18.35% | 19.50% | 20.41% |
| *I.1 ចំណូលចរន្តសរុប* | *25.05%* | *23.63%* | *16.28%* | *18.17%* | *19.32%* | *20.21%* |
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករ | 11.72% | 10.52% | 7.27% | 8.05% | 8.26% | 8.47% |
| អគ្គនាយកដ្ឋានពន្ធដារ | 10.24% | 10.42% | 7.12% | 7.69% | 8.47% | 9.00% |
| ចំណូលមិនមែនសារពើពន្ធសរុប | 3.09% | 2.68% | 1.88% | 2.42% | 2.58% | 2.73% |
| *ក្នុងនោះ ចំណូលពន្ធផ្សេងៗ* | 0.28% | 0.29% | 0.23% | 0.22% | 0.18% | 0.19% |
| II. ចំណាយសរុប | 25.75% | 30.13% | 26.50% | 25.07% | 24.51% | 25.64% |
| *II.1 ចំណាយចរន្តសរុប* | *16.86%* | *17.91%* | *16.37%* | *15.94%* | *15.19%* | *16.55%* |
| បន្ទុកបុគ្គលិក | 7.74% | 8.26% | 8.26% | 7.75% | 7.18% | 8.79% |
| បន្ទុកមិនមែនបុគ្គលិក | 9.11% | 9.65% | 8.11% | 8.19% | 8.01% | 7.76% |
| *II.2 ចំណាយមូលធនសរុប* | *8.89%* | *12.22%* | *10.13%* | *9.13%* | *9.32%* | *9.09%* |
| ហិរញ្ញប្បទានក្នុងប្រទេសសរុប | *3.49%* | *5.75%* | *3.66%* | *5.39%* | *3.24%* | *3.11%* |
| ទូទាត់ការខ្ចី | 0.80% | 1.00% | 1.00% | 0.94% | 0.93% | 1.02% |
| ហិរញ្ញប្បទានក្រៅប្រទេស | 4.60% | 5.47% | 5.47% | 5.13% | 4.30% | 4.41% |
| III. អតិរេកចរន្ត | 8.20% | 5.72% | -0.10% | 2.23% | 4.13% | 3.66% |
| IV. និនភាព/អតិរេកសរុប | -0.53% | -6.33% | -11.55% | -6.72% | -5.01% | -5.23% |

*សម្គាល់ ÷ ចំណាយលោះនិវត្តន៍ នឹងត្រូវកត់ត្រាក្នុងចំណាយបៀវត្ស ចាប់ពីឆ្នាំ ២០១៩ តទៅ*

## ខ.១ ចំណាយតាមវិស័យរយៈពេលមធ្យម ២០២០-២០២៣

| ចំណាយតាមវិស័យ | 2020 ច្បាប់ | 2020 កែ. | 2021 ព្យ. | 2022 ព្យ. | 2023 ព្យ. |
|---|---|---|---|---|---|
| **ប៊ីលានរៀល** | | | | | |
| 1. ចំណាយសរុបតាមវិស័យ (រួមបញ្ចូលហិរញ្ញប្បទានក្រៅប្រទេស) | 33,340 | 29,322 | 29,570 | 31,177 | 35,599 |
| 1.1 ថ្នាក់ជាតិ | 31,096 | 28,206 | 28,299 | 29,755 | 33,987 |
| ក.វិស័យរដ្ឋបាលទូទៅ | 2,512 | 2,944 | 2,350 | 2,385 | 2,616 |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *17* | *17* | *17* | *17* | *17* |
| ខ.វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់ | 4,792 | 4,715 | 4,587 | 4,610 | 5,948 |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *86* | *86* | *20* | *20* | *20* |
| គ.វិស័យសង្គមកិច្ច | 8,158 | 8,167 | 7,239 | 7,311 | 8,614 |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *473* | *473* | *250* | *250* | *250* |
| ឃ.វិស័យសេដ្ឋកិច្ច | 7,996 | 7,916 | 7,570 | 8,183 | 9,192 |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *1,514* | *1,514* | *1,219* | *1,219* | *1,219* |
| ង.ចំណាយផ្សេងៗ | 7,638 | 4,464 | 6,553 | 7,266 | 7,616 |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *3,811* | *1,674* | *2,361* | *2,523* | *2,232* |
| 1.2 ថ្នាក់ក្រោមជាតិ | 3,329 | 2,054 | 2,283 | 2,660 | 3,067 |
| 2. ចំណាយសរុបតាមវិស័យ (មិនរួមបញ្ចូលហិរញ្ញប្បទានក្រៅប្រទេស) | 27,286 | 23,269 | 24,104 | 25,057 | 28,589 |
| 1.1 ថ្នាក់ជាតិ | 25,043 | 22,153 | 22,833 | 23,636 | 26,978 |
| ក.វិស័យរដ្ឋបាលទូទៅ | 2,367 | 2,799 | 2,186 | 2,202 | 2,406 |
| *ក្នុងនោះ ចំណាយចរន្ត* | *2,351* | *2,782* | *2,170* | *2,185* | *2,390* |
| ខ.វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់ | 4,746 | 4,670 | 4,587 | 4,610 | 5,948 |
| *ក្នុងនោះ ចំណាយចរន្ត* | *4,660* | *4,584* | *4,567* | *4,590* | *5,928* |
| គ.វិស័យសង្គមកិច្ច | 7,220 | 7,230 | 6,856 | 6,883 | 8,124 |
| *ក្នុងនោះ ចំណាយចរន្ត* | *6,748* | *6,757* | *6,607* | *6,633* | *7,874* |
| ឃ.វិស័យសេដ្ឋកិច្ច | 3,071 | 2,991 | 2,651 | 2,675 | 2,884 |
| *ក្នុងនោះ ចំណាយចរន្ត* | *1,557* | *1,477* | *1,432* | *1,456* | *1,665* |
| ង.ចំណាយផ្សេងៗ | 7,638 | 4,464 | 6,553 | 7,266 | 7,616 |
| *ក្នុងនោះ ចំណាយចរន្ត* | *2,721* | *1,684* | *3,007* | *3,320* | *3,836* |
| ឧបត្ថម្ភធនជូនថ្នាក់ក្រោមជាតិ | 1,085 | 939 | 1,011 | 1,239 | 1,456 |
| 1.2 ថ្នាក់ក្រោមជាតិ | 3,329 | 2,054 | 2,283 | 2,660 | 3,067 |
| **ផលធៀបនឹងផ.ស.ស** | 2020 ច្បាប់ | 2020 កែ. | 2021 ព្យ. | 2022 ព្យ. | 2023 ព្យ. |
| 1. ចំណាយសរុបតាមវិស័យ (រួមបញ្ចូលហិរញ្ញប្បទានក្រៅប្រទេស) | 30.13% | 26.50% | 25.07% | 24.51% | 25.64% |
| 1.1 ថ្នាក់ជាតិ | 28.10% | 25.49% | 23.99% | 23.39% | 24.48% |
| ក.វិស័យរដ្ឋបាលទូទៅ | 2.27% | 2.66% | 1.99% | 1.88% | 1.88% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *0.01%* | *0.01%* | *0.01%* | *0.01%* | *0.01%* |
| ខ.វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់ | 4.33% | 4.26% | 3.89% | 3.62% | 4.28% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *0.08%* | *0.08%* | *0.02%* | *0.02%* | *0.01%* |
| គ.វិស័យសង្គមកិច្ច | 7.37% | 7.38% | 6.14% | 5.75% | 6.20% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *0.43%* | *0.43%* | *0.21%* | *0.20%* | *0.18%* |
| ឃ.វិស័យសេដ្ឋកិច្ច | 7.23% | 7.15% | 6.42% | 6.43% | 6.62% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *1.37%* | *1.37%* | *1.03%* | *0.96%* | *0.88%* |
| ង.ចំណាយផ្សេងៗ | 6.90% | 4.03% | 5.56% | 5.71% | 5.49% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *3.44%* | *1.51%* | *2.00%* | *1.98%* | *1.61%* |
| 1.2 ថ្នាក់ក្រោមជាតិ | 3.01% | 1.86% | 1.94% | 2.09% | 2.21% |
| 2. ចំណាយសរុបតាមវិស័យ (មិនរួមបញ្ចូលហិរញ្ញប្បទានក្រៅប្រទេស) | 24.66% | 21.03% | 20.44% | 19.70% | 20.59% |
| 1.1 ថ្នាក់ជាតិ | 22.63% | 20.02% | 19.36% | 18.58% | 19.43% |
| ក.វិស័យរដ្ឋបាលទូទៅ | 2.14% | 2.53% | 1.85% | 1.73% | 1.73% |
| *ក្នុងនោះ ចំណាយចរន្ត* | *2.12%* | *2.51%* | *1.84%* | *1.72%* | *1.72%* |
| ខ.វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់ | 4.29% | 4.22% | 3.89% | 3.62% | 4.28% |
| *ក្នុងនោះ ចំណាយចរន្ត* | *4.21%* | *4.14%* | *3.87%* | *3.61%* | *4.27%* |
| គ.វិស័យសង្គមកិច្ច | 6.53% | 6.53% | 5.81% | 5.41% | 5.85% |
| *ក្នុងនោះ ចំណាយចរន្ត* | *6.10%* | *6.11%* | *5.60%* | *5.21%* | *5.67%* |
| ឃ.វិស័យសេដ្ឋកិច្ច | 2.78% | 2.70% | 2.25% | 2.10% | 2.08% |
| *ក្នុងនោះ ចំណាយចរន្ត* | *1.41%* | *1.33%* | *1.21%* | *1.14%* | *1.20%* |
| ង.ចំណាយផ្សេងៗ | 6.90% | 4.03% | 5.56% | 5.71% | 5.49% |
| *ក្នុងនោះ ចំណាយចរន្ត* | *2.46%* | *1.52%* | *2.55%* | *2.61%* | *2.76%* |
| ឧបត្ថម្ភធនជូនថ្នាក់ក្រោមជាតិ | 0.98% | 0.85% | 0.86% | 0.97% | 1.05% |
| 1.2 ថ្នាក់ក្រោមជាតិ | 3.01% | 1.86% | 1.94% | 2.09% | 2.21% |